ទីស្ដីការគណៈរដ្ឋមន្ត្រី

# ការវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត នៅកម្ពុជា

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ដាក់ឲ្យប្រើប្រាស់នៅខែសីហា ២០១៤

# មាតិកា


សេចក្តីផ្តើម ............................................................ ៣

អ្វីទៅជាការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIA)?............................................................ ៦

ដំណាក់កាលទាំងពីរក្នុងវិធីអនុវត្ត RIA ............................ ១០

RIA នៅក្នុងការរៀបចំតាក់តែងបទប្បញ្ញត្តិ........................ ១២

ការវាយតម្លៃបឋមលើផលប៉ះពាល់ (PAS) ............................ ១៤

ការរៀបចំ និងការវាយតម្លៃ ............................................ ១៧

ការកំណត់បញ្ហា ............................................................ ២១

ការបង្ហាញអំពីគោលបំណងនៃកិច្ចអន្តរាគមន៍ .................. ២៦

ការជ្រើសរើសនូវជម្រើសសម្រាប់ធ្វើការវិភាគ .................. ៣១

ការពិចារណាលើបន្ទុកចំណាយនិងផលចំណេញ ............ ៣៤

ការវិភាគតាមក្រុមក្នុងសង្គមនិងតាមគុណភាព .................. ៥១

ប្រសិទ្ធភាពនៃការពិគ្រោះយោបល់ .................................. ៥៥

ការជ្រើសរើសនូវជម្រើសដែលសមស្របជាងគេ ............... ៦១

ការធានាថាបញ្ញត្តិកម្មដែលជ្រើសរើសអាចអនុវត្តបាន........ ៦៤

ឧបសម្ព័ន្ធ១ ............................................................ ៦៨

ឧបសម្ព័ន្ធ២ ............................................................ ៧៨

ឧបសម្ព័ន្ធ៣ ............................................................ ៨៤

# សេចក្តីផ្តើម

## អំពីគម្រោងនៃការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (គម្រោងRIA) នៅកម្ពុជា

គម្រោងRIA (Regulatory Impact Assessement) នៅកម្ពុជា សំដៅពង្រឹងភាពប្រកួតប្រជែង និងប្រសិទ្ធភាពនៃបញ្ញត្តិកម្ម តាមរយៈការបង្កើតនូវគោលការណ៍ប្រតិបត្តិល្អក្នុងនីតិវិធីតាក់តែងលិខិតបទដ្ឋាន-គតិយុត្តនៅតាមក្រសួងស្ថាប័ននៃរាជរដ្ឋាភិបាល។ ប្រព័ន្ធ RIA តម្រូវឲ្យក្រសួងនីមួយៗអនុវត្តតាមគោលការណ៍ប្រតិបត្តិល្អ និងវាយតម្លៃលើគុណសម្បត្តិនៃបទប្បញ្ញត្តិ ដែលមានផលប៉ះពាល់ដល់បន្ទុកចំណាយកាតព្វកិច្ច និងការប្រកួតប្រជែងរបស់ធុរកិច្ច។

គម្រោងនេះ បានបង្កើតក្រុមការងារប្រតិបត្តិគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (Office of RIA-ORIA ឬ Executing Agency-EA) នៅក្នុងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីផ្តល់ការណែនាំអំពីគោលការណ៍ប្រតិបត្តិល្អ ក្នុងនីតិវិធីតាក់តែងលិខិតបទដ្ឋានគតិយុត្ត ការបណ្តុះបណ្តាលអំពីRIA និងការគាំទ្រក្នុងការអនុវត្តRIA ដល់ក្រសួងស្ថាប័នពាក់ព័ន្ធ និងទទួលគ្រប់គ្រងដំណើរការនៃគម្រោងទាំងមូល។

គម្រោងចាប់ផ្តើមដំណើរការដំបូង ជាមួយក្រសួងទីភ្នាក់ងារអនុវត្តគម្រោង (Implementing Agency-IA) រួមមាន ក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន អតីតក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល និងក្រសួងទេសចរណ៍ ដើម្បីពិសោធអនុវត្តវិធីសាស្ត្រRIA ក្នុងអំឡុងវគ្គបណ្តុះបណ្តាលនៃគម្រោងសម្រាប់រៀបចំតាក់តែងសំណើបញ្ញត្តិកម្ម

ដូចបានកំណត់នៅក្នុងផែនការសកម្មភាពដែលIAនីមួយៗបានលើកឡើងក្នុងអំឡុងពេលចាប់ផ្តើមគម្រោងក្នុងឆ្នាំ២០១១។

គម្រោងមានរយៈពេល៣០ខែ ចាប់ពីខែតុលា ឆ្នាំ២០១១ ដែលអនុវត្តដោយEA និងIA ដោយមានជំនួយពីក្រុមទីប្រឹក្សាអន្តរជាតិ និងអ្នកជំនាញក្នុងប្រទេស រហូតដល់ខែមីនា ឆ្នាំ២០១៣។ ក្រោយពីទទួលបានរបាយការណ៍វាយតម្លៃពាក់កណ្តាលដំណើរការគម្រោង ធ្វើឡើងនៅខែមិថុនា ឆ្នាំ២០១៣ ដោយធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ស្តីពីជោគជ័យនៃការអនុវត្តគម្រោង រាជរដ្ឋាភិបាលនិងADB បានឯកភាពបញ្ចូលក្រសួង៣ទៀតក្នុងកម្មវិធីគម្រោង នៅខែមករា ឆ្នាំ២០១៤ គឺមានក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជននិងកីឡា និងឲ្យបន្តគម្រោង ៦ខែ(មេសា-កញ្ញា)ទៀត។

ECOSOCCនិងADB បានធ្វើការផ្សព្វផ្សាយគម្រោងRIAនៅតាមក្រសួងស្ថាប័នសាកលវិទ្យាល័យនានា អគ្គលេខាធិការដ្ឋានរដ្ឋសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជាមួយវិស័យឯកជន និងសង្គមស៊ីវិលបានចំនួន៣១ដងមកហើយមានអ្នកចូលរួមប្រមាណជាង៩៥០០នាក់ ដែលទាំងអស់បានគាំទ្រយ៉ាងខ្លាំងដល់វិធីសាស្រ្តRIA និងចង់បានRIAអនុវត្តនៅប្រទេសកម្ពុជា។

សម្រាប់ព័ត៌មានលម្អិតអំពីគម្រោងRIA ក្នុងប្រទេសកម្ពុជា អ្នកអាចចូលមើលក្នុងគេហទំព័រ (www.ecosocc.gov.kh)។ ប្រសិនបើអ្នកចង់យល់ដឹងទិដ្ឋភាពរួមអំពីRIA អ្នកអាចទាក់ទងមកORIA ដើម្បីឲ្យមន្រ្តីORIAធ្វើបទបង្ហាញជូន។

## អំពីសៀវភៅនេះ

សៀវភៅណែនាំនេះបង្ហាញអំពីគោលការណ៍នៃវិធីអនុវត្តRIA នៅក្នុងប្រទេសកម្ពុជា និងតម្រូវការឲ្យមន្ត្រីRIAបំពេញតាមធាតុនីមួយៗ នៃការវាយតម្លៃលើផលប៉ះពាល់ឲ្យបានត្រឹមត្រូវ។ គោលបំណង គឺជួយមន្ត្រីរាជរដ្ឋាភិបាលក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងផ្តល់នូវព័ត៌មានឲ្យបានសុក្រឹតជូនថ្នាក់ដឹកនាំ។

សៀវភៅណែនាំនេះ គឺជាឯកសារមូលដ្ឋាន។ សៀវភៅបោះពុម្ពផ្សាយលើកទី២នេះ បានកែលម្អឡើងក្រោយពីបានបោះពុម្ពផ្សាយលើកទី១ ដែលមានគោលបំណងជួយដល់មន្ត្រីក្នុងអំឡុងពេលបង្កើតORIA និងអភិវឌ្ឍន៍RIAសម្រាប់សំណើបញ្ញត្តិកម្ម ដែលមានក្នុងផែនការសកម្មភាពរបស់IAនីមួយៗ។ ដូច្នេះ ការបោះពុម្ពផ្សាយនេះផ្តោតសំខាន់លើការបង្ហាញអំពីគោលការណ៍ប្រតិបត្តិល្អ ក្នុងការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត និងបង្ហាញទិដ្ឋភាពទូទៅនៃវិធីអនុវត្តRIA។

សៀវភៅណែនាំនេះ ត្រូវបានរៀបចំដោយមានជំនួយការពីទីប្រឹក្សាមកពីក្រុមហ៊ុន POHL & Associates ពីប្រទេសអាល្លឺម៉ង់ដែលមានលោក Sabesh Sivasabesh លោក Steve Rowley និងលោក Sam Gow និងការចូលរួមយ៉ាងសកម្មពីឯកឧត្តម យឹម ណុលសន ឯកឧត្តម ប៉ិច សុខា ឯកឧត្តម អេង វត្ដមុនី ឯកឧត្តមបណ្ឌិត ម៉ម សារិទ្ធ ឯកឧត្តម ឆយ អូន និងពីមន្ត្រី ORIA ផ្សេងទៀត ។

# តើអ្វីទៅជាការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត?

## ការវាយតម្លៃជាប្រព័ន្ធនៃសំណើបញ្ញត្តិកម្មថ្មី

គោលបំណងRIA គឺដើម្បីកែលម្អភាពមាំមួននៃការធ្វើច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងប្រទេសកម្ពុជា ដោយធានាថា៖

- ជម្រើសនីមួយៗត្រូវបានយកមកពិចារណា ដោយធានាបាននូវប្រសិទ្ធភាពរបស់បញ្ញត្តិកម្មដែលនឹងត្រូវបង្កើត
- បញ្ញត្តិកម្មមិនត្រូវបានធ្វើនៅពេលដែលវាបង្ហាញថាជាជម្រើសមិនល្អ
- មានការពិគ្រោះយោបល់ជាសាធារណៈក្នុងកម្រិតទទួលយកបាន។

ការអនុវត្តការវាយតម្លៃជាប្រព័ន្ធនៃសំណើបញ្ញត្តិកម្ម ដែលមានធាតុទាំង៧ (តារាង១) នឹងធ្វើឲ្យបញ្ញត្តិកម្មត្រូវបានធ្វើការសាកល្បង ហើយជម្រើសនីមួយៗត្រូវបានយកមកពិចារណាដោយស្មើៗគ្នា។

គោលការណ៍ចម្បងបី នឹងណែនាំអំពីការរៀបចំ RIA ៖

- **ការកែលម្អព័ត៌មានសម្រាប់ថ្នាក់ដឹកនាំ** ៖ RIA នឹងផ្តល់ព័ត៌មានស្តីពីបន្ទុកចំណាយនិងផលចំណេញនៃសំណើបញ្ញត្តិកម្ម និងជម្រើសដែលសម្រេចនូវគោលបំណងដូចគ្នា ជូនថ្នាក់

ដឹកនាំ ដើម្បីធ្វើសេចក្តីសម្រេចប្រកបដោយព័ត៌មានសុក្រឹតគ្រប់គ្រាន់។

- **ភាពងាយស្រួល** ៖ ភាគច្រើននៃផលចំណេញនានារបស់ RIAអាចទទួលបានតាមរយៈការពិគ្រោះយោបល់ ហេតុផលសមរម្យ ការងាយស្រួលគណនា និងការសាកល្បងលើការសន្មតជាជាងតាមរយៈការអនុវត្តបច្ចេកទេសស្មុគស្មាញ។ ដូច្នេះ RIAដែលអនុវត្តនៅកម្ពុជា នឹងមានភាពងាយស្រួលអនុវត្ត។
- **តម្លាភាព** ៖ តម្លាភាពអាចធ្វើឲ្យមានការពិគ្រោះយោបល់បានត្រឹមត្រូវ និងអភិបាលកិច្ចបានល្អ ហើយសម្រេចបានដោយចំណាយតិចតាមរយៈការបង្ហោះព័ត៌មានលើគេហទំព័រ។ ដើម្បីជួយដល់អាជីវកម្មតូចៗដែលមិនមានលទ្ធភាពប្រើប្រាស់អ៊ីនធឺណិត ភាពងាយស្រួលមើលឯកសារសាធារណៈត្រូវបានរក្សាទុកដើម្បីឲ្យភាគីពាក់ព័ន្ធអាចមើលឯកសារនោះបាន។

 ការកែលម្អតម្លាភាព នឹងជួយឲ្យសម្រេចគោលបំណងចុងក្រោយរបស់គម្រោង។

## តារាងទី១- ធាតុទាំងប្រាំពីរនៃ RIA

### បញ្ហា

- កំណត់អត្តសញ្ញាណនៃបញ្ហាដែលត្រូវដោះស្រាយ។ រៀបរាប់ពីសញ្ញាបុព្វហេតុ និងអ្នកដែលរងផលប៉ះពាល់។ ផ្តល់ភស្តុតាងជាក់លាក់ និងពន្យល់ថាហេតុអ្វីបានជាលិខិតបទដ្ឋានដែលមានស្រាប់ មិនអាចដោះស្រាយបាន។

### គោលបំណង

- កំណត់គោលបំណងដែលត្រូវអន្តរាគមន៍ ក្នុងរូបភាពជាលទ្ធផលជាជាងជាមធ្យោបាយ ដើម្បីសម្រេចបានលទ្ធផល។

### ជម្រើស

- កំណត់ជម្រើសផ្សេងៗ ដោយបោះបង់ចោលនូវជម្រើសដែលមិនអាចដោះស្រាយបញ្ហាបានឬមិនសមស្រប និងរៀបរាប់ដោយលម្អិតអំពីជម្រើសដែលអាចដោះស្រាយបញ្ហាបាន ។

### ការវិភាគផលប៉ះពាល់

- កំណត់និងប៉ាន់ស្មានលើបន្ទុកចំណាយនិងផលចំណេញ ក៏ដូចជាវាយតម្លៃអំពីផលប៉ះពាល់ដល់យេនឌ័រ និងការប្រកួតប្រជែងនៃជម្រើសទាំងនោះ។

## ការពិគ្រោះយោបល់

- ធ្វើការពិគ្រោះយោបល់ជាមួយអ្នកដែលពាក់ព័ន្ធ ក្នុងអំឡុងពេលរៀបចំPASឬRIS និងប្រើប្រាស់លទ្ធផលនៃការពិគ្រោះយោបល់នោះ ដើម្បីបំពេញបន្ថែមដល់ធាតុទាំង៦ផ្សេងទៀតរបស់RIA។

## សេចក្តីសន្និដ្ឋាន

- កំណត់ជម្រើសដែលសមស្របជាងគេ ដែលមានប្រសិទ្ធភាពបំផុត ដើម្បីសម្រេចគោលបំណងនៃការអន្តរាគមន៍ និងផ្តល់នូវផលចំណេញខ្ពស់ដល់សង្គម។

## ការអនុវត្ត និងការតាមដានត្រួតពិនិត្យ

- ពន្យល់ថា តើជម្រើសដែលឃើញសមស្របជាងគេនោះ នឹងត្រូវបានអនុវត្តនិងវាយតម្លៃយ៉ាងដូចម្តេច?

# ដំណាក់កាលទាំងពីរក្នុងវិធីអនុវត្ត RIA

## តម្រង់គោលដៅអនុវត្ត RIA ឲ្យចំទិស

ដើម្បីឲ្យការងាររដ្ឋបាលមានភាពងាយស្រួល និងនីតិវិធីមានប្រសិទ្ធភាព វីធីអនុវត្តRIAមានពីរដំណាក់កាល ត្រូវបានស្នើឡើងសម្រាប់អនុវត្តក្នុងប្រទេសកម្ពុជា។

- រាល់សំណើបញ្ញត្តិកម្មដែលមានផលប៉ះពាល់ដល់ធុរកិច្ច តម្រូវឲ្យធ្វើ**ការវាយតម្លៃបឋមលើផលប៉ះពាល់ (PAS)**
- **ប្រសិនបើការវាយតម្លៃបឋមលើផលប៉ះពាល់បង្ហាញថា សំណើបញ្ញត្តិកម្មនោះមានផលប៉ះពាល់អវិជ្ជមានគួរឲ្យកត់សម្គាល់ដល់សេដ្ឋកិច្ច សង្គមកិច្ច ឬដល់ការប្រកួតប្រជែង តម្រូវឲ្យធ្វើការវាយតម្លៃពេញលេញលើផលប៉ះពាល់ (RIS)។**

ដំណាក់កាលនៃដំណើរការនេះ ត្រូវបានបង្ហាញក្នុងរូបភាពទី១។

ទាំងPAS ទាំងRIS ត្រូវមានការវិភាគតាមធាតុទាំង៧របស់RIA។ គោលបំណងរបស់PAS គឺវាយតម្លៃឲ្យបានរហ័សលើសំណើបញ្ញត្តិកម្មដើម្បីបង្ហាញថា តើសំណើបញ្ញត្តិកម្មនោះមានផលប៉ះពាល់ គួរឲ្យកត់សម្គាល់ឬទេ។ សំណើបញ្ញត្តិកម្មណាដែលមិនមានផលប៉ះពាល់គួរឲ្យកត់សម្គាល់ មិនតម្រូវឲ្យធ្វើការវិភាគបន្តទៀតទេ។ សំណើបញ្ញត្តិកម្មដែលមានផលប៉ះពាល់គួរឲ្យកត់សម្គាល់ តម្រូវឲ្យធ្វើRISដោយមានការវាយតម្លៃស៊ីជម្រៅ។

- ការតម្រូវឲ្យមានPASចំពោះសំណើបញ្ញត្តិកម្មទាំងអស់ នឹងធានាថា ពុំមានសំណើបញ្ញត្តិកម្មណាគេចផុតពីការត្រួតពិនិត្យយ៉ាងហ្មត់ចត់បានទេ
- ការតម្រូវឲ្យធ្វើRIS នឹងធានាថា ការវាយតម្លៃត្រូវបានធ្វើលើរាល់សំណើបញ្ញត្តិកម្មណា ដែលមានផលប៉ះពាល់គួរឲ្យកត់សម្គាល់។

ក្នុងអំឡុងវគ្គបណ្ដុះបណ្ដាលនៃគម្រោង មានតែសំណើបញ្ញត្តិកម្មរបស់ទីភ្នាក់ងារអនុវត្តគម្រោងទេដែលនឹងតម្រូវឲ្យធ្វើPAS ហើយសំណើបញ្ញត្តិកម្មមួយចំនួន ដែលមានផលប៉ះពាល់គួរឲ្យកត់សម្គាល់នឹងត្រូវធ្វើRIS។

## រូបភាពទី១ : ទិដ្ឋភាពរួមនៃដំណាក់កាលទាំងពីរក្នុងការអនុវត្ត RIA



# RIA នៅក្នុងការរៀបចំតាក់តែងបញ្ញត្តិកម្ម

## រូបភាពទី២ - ដំណើររៀបចំតាក់តែងបញ្ញត្តិកម្មថ្មី




## RIA និងដំណើរការរៀបចំតាក់តែងបញ្ញត្តិកម្ម

RIA ផ្ដល់ព័ត៌មានអំពីបន្ទុកចំណាយនិងផលចំណេញ និងជម្រើសផ្សេងៗ ដែលអាចសម្រេចគោលបំណងដូចគ្នា ជូនថ្នាក់ដឹកនាំដើម្បីសម្រេចដោយមានព័ត៌មានគ្រប់គ្រាន់។

រូបភាពទី២ បង្ហាញអំពីភាពស៊ីចង្វាក់របស់RIAនៅក្នុងដំណើរការរៀបចំតាក់តែងបញ្ញត្តិកម្មនៅក្នុងប្រទេសកម្ពុជា។ RIA ត្រូវបានរៀបចំឡើងដោយក្រសួងដែលជាអ្នកកំណត់អំពីភាពចាំបាច់នៃកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាល ហើយដាក់សំណើបញ្ញត្តិកម្មជូនថ្នាក់ដឹកនាំ។

- ចំពោះច្បាប់ ព្រះរាជក្រឹត្យ និងអនុក្រឹត្យ ក្រសួងសាមីត្រូវរៀបចំPAS ហើយបើតម្រូវ ត្រូវរៀបចំRIS មុននឹងដាក់សំណើបញ្ញត្តិកម្មជូនអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល។
- ចំពោះប្រកាស បទបញ្ជា និងសារាចរ ក្រសួងសាមីត្រូវរៀបចំ PAS ហើយបើតម្រូវ ត្រូវរៀបចំRIS មុននឹងដាក់សំណើបញ្ញត្តិកម្មជូនរដ្ឋមន្ត្រីរបស់ខ្លួន។

## វិធីអនុវត្ត RIA ក្នុងដំណាក់កាលបណ្តោះអាសន្ន

ក្នុងអំឡុងវគ្គបណ្តុះបណ្តាលនៃគម្រោង វិធីអនុវត្តRIAនឹងប្រតិបត្តិតែលើសំណើបញ្ញត្តិកម្មណាដែលមាននៅក្នុងផែនការសកម្មភាពរបស់IAតែប៉ុណ្ណោះ។

នៅដំណាក់កាលដំបូង IAនិងORIAសហការគ្នាក្នុងការធ្វើPAS និងRIS ដោយមានជំនួយពីអ្នកជំនាញការអន្តរជាតិ ដើម្បីរៀនសូត្រអំពីវិធីនៃការធ្វើវិភាគឲ្យបានល្អ។

តាំងពីឆ្នាំ២០១២ ORIAដើរតួនាទីជាអ្នកកសាងសមត្ថភាព និងជាអ្នកវាយតម្លៃ។ IAនឹងរៀបចំPASនិងRIS ដោយគ្មានឬមានជំនួយតិចតួចពីអ្នកជំនាញការអន្តរជាតិ (ជំនួយនឹងត្រូវផ្តល់ទៅថ្ងៃមុខ ដោយ ORIA) ។ PAS/RIS នឹងត្រូវដាក់ជូនORIA ដើម្បីពិនិត្យ។

យើងសង្ឃឹមថា នៅពេលដែលសមត្ថភាពចេះធ្វើនិងវាយតម្លៃ RIAត្រូវបានអភិវឌ្ឍរួច ដំណើរការខាងលើនេះនឹងត្រូវអនុវត្តដោយក្រសួងទាំងអស់។

# ការវាយតម្លៃបឋមលើផលប៉ះពាល់

## ការវាយតម្លៃបឋមលើផលប៉ះពាល់

ការវាយតម្លៃបឋមលើផលប៉ះពាល់ (PAS) ត្រូវបានធ្វើឡើងដោយប្រើប្រាស់ទម្រង់ដូចមានក្នុងឧបសម្ព័ន្ធ១ ហើយចាប់ផ្តើមសាកល្បងថាតើសំណើបញ្ញត្តិកម្មឈានដល់កម្រិតដែលត្រូវធ្វើRIS ឬទេ។

ដំណាក់កាលដំបូងនៃការសាកល្បងនេះ គឺដើម្បីកំណត់ថាតើសំណើនោះមានលក្ខណៈជាបញ្ញត្តិកម្មឬទេ មានន័យថាតើសំណើនោះមានលក្ខណៈចាប់បង្ខំបុគ្គល ធុរកិច្ច ឲ្យផ្លាស់ប្តូរឥរិយាបថឬទេ។ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស គឺជាបញ្ញត្តិកម្ម។ ឯកសាររដ្ឋាភិបាលផ្សេងទៀត ដែលមានលក្ខណៈចាប់បង្ខំធុរកិច្ចក៏មានលក្ខណៈជាបញ្ញត្តិកម្មដែរ។

ដំណាក់កាលទី២នៃការសាកល្បងនេះ គឺកំណត់ថាតើសំណើនោះមានផលប៉ះពាល់ដល់ធុរកិច្ចឬទេ។ ផលប៉ះពាល់ដល់ធុរកិច្ចមានស្ថានភាពដូចខាងក្រោម ៖

- បន្ថែមបន្ទុកចំណាយដល់ធុរកិច្ច
- មិនលើកទឹកចិត្តដល់វិនិយោគឯកជន
- ដាក់ការរឹតត្បិតចំពោះការចាកចេញ ឬការចូលទៅក្នុងទីផ្សាររបស់ធុរកិច្ច
- ប៉ះពាល់ដល់លទ្ធភាពរបស់ធុរកិច្ចក្នុងការច្នៃប្រឌិត
- ធ្វើឲ្យអ្នកប្រើប្រាស់មានការពិបាកក្នុងការផ្លាស់ប្តូរអ្នកផ្តល់សេវា
- កាត់បន្ថយភាពងាយស្រួល ដល់ការរកទិញ តម្លៃឬគុណភាពទំនិញ និងសេវានៅក្នុងទីផ្សារ។

ប្រសិនបើស្ថានភាពខាងលើនេះកើតឡើងចំពោះធុរកិច្ចមែន នោះ តម្រូវឲ្យបន្តធ្វើPASទៅតាមធាតុទាំង៧នៃRIA ដោយឈរលើមូលដ្ឋាននៃការវិភាគគុណភាព ថ្វីបើការវាយតម្លៃលើផលប៉ះពាល់នោះជាបរិមាណក៏ដោយ ក៏ជាការអនុវត្តល្អដែរ។

សេចក្តីព្រាងPAS នឹងត្រូវដាក់ជូនORIA ដើម្បីពិនិត្យ។

ប្រសិនបើPASបង្ហាញថាមានផលប៉ះពាល់តិចតួច នោះមិនតម្រូវឲ្យវិភាគតទៅទៀតទេ។ PASនិងសំណើបញ្ញត្តិកម្មត្រូវដាក់ជូនថ្នាក់ដឹកនាំ និងបង្ហោះលើគេហទំព័រ ECOSOCC។

## រូបភាពទី៣ - ការសាកល្បង

| | |
|---|---|
| ដំណាក់កាលទី១ តើសំណើនោះជាបញ្ញត្តិកម្ម? | តើសំណើបញ្ញត្តិកម្មមានលក្ខណៈចាប់បង្ខំឬ? តើមានការបង្ខំឲ្យអនុវត្តជាជាងការអនុវត្តដោយស្ម័គ្រចិត្ត? |
| ដំណាក់កាលទី២ តើសំណើបញ្ញត្តិកម្មមានផលប៉ះពាល់ដល់ធុរកិច្ចឬទេ? | តាមរយៈ ៖<br>. បន្ថែមបន្ទុកចំណាយដល់ធុរកិច្ច<br>. មិនលើកទឹកចិត្តដល់វិនិយោគឯកជន<br>. ដាក់ការរឹតត្បិតធុរកិច្ចក្នុងការចាកចេញនិងការចូលទៅក្នុងទីផ្សារ<br>. ប៉ះពាល់លទ្ធភាពរបស់ធុរកិច្ចក្នុងការច្នៃប្រឌិត<br>. ធ្វើឲ្យអ្នកប្រើប្រាស់មានការពិបាកក្នុងការផ្លាស់ប្តូរអ្នកផ្តល់សេវា<br>. កាត់បន្ថយភាពងាយស្រួលដល់ការរកទិញតម្លៃឬគុណភាពទំនិញ និងសេវានៅក្នុងទីផ្សារ |

## សំណួរមពរដែលតែងតែសួរពាក់ព័ន្ធនឹងការវាយតម្លៃបឋមលើផលប៉ះពាល់?

***តើយើងត្រូវការវាយតម្លៃបឋមលើផលប៉ះពាល់(PAS)ដែរឬទេ?***
ប្រសិនបើសំណើបញ្ញត្តិកម្មត្រូវបានយកមកពិចារណា យើងត្រូវធ្វើ PASដើម្បីវាយតម្លៃថា តើសំណើនោះមានផលប៉ះពាល់ដល់ធុរកិច្ចឬទេ?

***តើយើងធ្វើយ៉ាងណា ដើម្បីឲ្យដឹងថាបន្ទុកចំណាយទាប?***
បន្ទុកចំណាយទាបកើតឡើងនៅពេលដែលមានធុរកិច្ចមួយចំនួនតូចទទួលរងផលប៉ះពាល់ ឬធុរកិច្ចមានបន្ទុកចំណាយតែមួយដង។

***តើយើងត្រូវគិតពីផលចំណេញដែរឬទេ ខណៈពេលគិតពីផលប៉ះពាល់?***
ផលប៉ះពាល់ដល់ធុរកិច្ច គួរត្រូវបានវាយតម្លៃលើបន្ទុកចំណាយ **ឬលើផលប៉ះពាល់អវិជ្ជមានតែប៉ុណ្ណោះ។** បន្ទុកចំណាយមិនគួរទូទាត់នឹងផលចំណេញទេ នៅដំណាក់កាលនេះ។ ការអនុវត្តនេះវាជាផ្នែករបស់RIA។

# ការរៀបចំ និងការវាយតម្លៃ

## ដំណើរការរៀបចំសេចក្តីព្រាង និងការវាយតម្លៃ



## ការរៀបចំនិងការវាយតម្លៃ RIA

វិធីអនុវត្តRIA ត្រូវប្រតិបត្តិដោយORIAជាមួយមន្ត្រីនៃIA។ IA នឹងទទួលខុសត្រូវក្នុងការកំណត់សំណើបញ្ញត្តិកម្មដែលនឹងត្រូវធ្វើRIS។

បន្ទាប់ពីបានកំណត់សំណើបញ្ញត្តិកម្ម IAនឹងរៀបចំPAS។ IAអាចស្នើសុំជំនួយឬការណែនាំពីORIA ដើម្បីបញ្ចប់សេចក្តីព្រាងPAS របស់ខ្លួន។ IA ផ្ញើសេចក្តីព្រាងPAS ចុងក្រោយមកORIA ដើម្បីពិនិត្យ។ ORIAពិនិត្យវិនិច្ឆ័យសេចក្តីព្រាងPAS ដោយធ្វើការផ្ទៀងផ្ទាត់ជាមួយបញ្ជីត្រួតពិនិត្យដែលមានក្នុងឧបសម្ព័ន្ធ២ និងវាយតម្លៃថាគ្រប់គ្រាន់ឬមិនទាន់គ្រប់គ្រាន់។ ប្រសិនបើវាមិនទាន់គ្រប់គ្រាន់ PASនោះនឹងត្រូវផ្ញើត្រឡប់ទៅIAវិញ ដោយភ្ជាប់យោបល់របស់ORIA។ IAនឹងធ្វើការកែសម្រួលតាមយោបល់របស់ORIA រហូតដល់សេចក្តីព្រាងPASនោះមានលក្ខណៈគ្រប់គ្រាន់ (ដំណើរការនេះអាចធ្វើច្រើនដង)។

ក្នុងករណីសេចក្តីព្រាងPASមានលក្ខណៈគ្រប់គ្រាន់ IAនឹងធ្វើ RISប្រសិនបើតម្រូវ ឬដាក់PASនិងសំណើបញ្ញត្តិកម្មជូនថ្នាក់ដឹកនាំ។

នីតិវិធីនៃការវិភាគRIS ត្រូវអនុវត្តដូចធ្វើPAS ដែរ ។

## វិធីអនុវត្តក្នុងដំណាក់កាលបណ្តោះអាសន្ន

ក្នុងដំណាក់កាលបណ្តុះបណ្តាលORIAនិងIAនឹងសហការគ្នាក្នុងការធ្វើPAS/RIS ខណៈពេលកំពុងសិក្សាអំពីធាតុទាំង៧របស់RIAតាមរយៈវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលាដែលរៀបចំដោយទីប្រឹក្សាអន្តរជាតិ។

ដំណើរការខាងលើនេះនឹងចាប់ផ្តើមអនុវត្តនៅពេលIAនិងORIA មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការព្រាងនិងវាយតម្លៃPASនិង RIS ។

# ធាតុទាំងប្រាំពីរ
# នៃការវាយតម្លៃលើផលប៉ះពាល់
# នៃលិខិតបទដ្ឋានគតិយុត្ត

# ការកំណត់បញ្ហា

## ធាតុទី១ - បញ្ហា

ដំណាក់កាលទី១របស់RIA គឺកំណត់លក្ខណៈនិងទំហំនៃបញ្ហាដែលត្រូវដោះស្រាយ។

ការរកឲ្យឃើញបញ្ហាដែលកើតមានឡើង វាមានសារៈសំខាន់មុននឹងសម្រេចថា តើអន្តរាគមន៍របស់រដ្ឋាភិបាល ដូចជាការដាក់បញ្ញត្តិកម្ម គឺជាការចាំបាច់ឬទេ។ ប្រសិនបើមិនបានយល់ច្បាស់លាស់អំពីប្រភពលក្ខណៈ និងទំហំនៃបញ្ហាទេ សំណើបញ្ញត្តិកម្មនោះអាចមិនគ្រប់គ្រាន់ មិនសមរម្យ ឬមិនមានប្រសិទ្ធភាព។

ការកំណត់បញ្ហាឲ្យបានច្បាស់លាស់ ជួយឲ្យមានការចាប់អារម្មណ៍ទៅលើអ្វីដែលចាំបាច់ត្រូវផ្លាស់ប្តូរ និងទំហំនៃការផ្លាស់ប្តូរនោះនឹងអាចជួយរកដំណោះស្រាយដែលមានសក្តានុពល។

កិច្ចអន្តរាគមន៍របស់រដ្ឋាភិបាល អាចមានហេតុផលត្រឹមត្រូវដើម្បីសម្រេចគោលបំណងសង្គម ឬបរិស្ថានដែលមិនអាចធ្វើឲ្យសម្រេចតាមរយៈទីផ្សារ។ កិច្ចអន្តរាគមន៍ទាំងនេះមានដូចខាងក្រោម ៖

- កែតម្រូវភាពបរាជ័យនៃទីផ្សារ
- ជំរុញលទ្ធផលឲ្យមានសមធម៌ ឬស្តង់ដារអប្បបរិមានៃការរស់នៅក្នុងសហគមន៍
- ធានាសុវត្ថិភាពសង្គម ដោយការពារប្រជាជនពីឧក្រិដ្ឋកម្ម និងអំពើរំលោភបំពាន

## បញ្ជីត្រួតពិនិត្យ - តើអ្នកអាចឆ្លើយសំណួរដូចខាងក្រោមនេះបានឬ ទេ?

តើបញ្ហានោះធំកម្រិតណា និងមានផលវិបាកធ្ងន់ធ្ងរកម្រិតណា ?
អ្វីជាផលប៉ះពាល់នៃបញ្ហា និងនរណារងផលប៉ះពាល់នោះ ?
តើអ្នកមានភស្តុតាង ឬឧទាហរណ៍ដើម្បីគាំទ្របញ្ហានោះទេ ?
ហេតុអ្វីបានជាបញ្ញត្តិកម្មដែលមានស្រាប់មិនអាចដោះស្រាយបញ្ហានោះបាន ?
តើមានអ្វីកើតឡើង ប្រសិនបើមិនចាត់វិធានការលើបញ្ហានោះ ?
តើកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាលអាចដោះស្រាយបញ្ហានោះបានឬទេ ?

## *ការកែតម្រូវភាពបរាជ័យនៃទីផ្សារ*

ជាទូទៅ ទីផ្សារដែលដំណើរការល្អបានផ្តល់មធ្យោបាយមានប្រសិទ្ធភាពក្នុងការបែងចែកទំនិញនិងសេវានៅក្នុងសហគមន៍ ធ្វើឲ្យមានសុខុមាលភាពច្រើននៅក្នុងសហគមន៍។ ទីផ្សារគឺជាមធ្យោបាយដ៏ល្អបំផុតក្នុងការធានាឲ្យមានការផលិតទំនិញ និងសេវាប្រកបដោយប្រសិទ្ធភាព។ ម្យ៉ាងទៀត ទីផ្សារប្រកួតប្រជែងជំរុញឲ្យមានការច្នៃប្រឌិត និងផ្តល់ជម្រើសកាន់តែច្រើនសម្រាប់អ្នកប្រើប្រាស់។

ទោះបីជាយ៉ាងណាក៏ដោយ មានករណីខ្លះ ទីផ្សារមិនបានផ្តល់លទ្ធផលល្អសម្រាប់សង្គមទេ ឧទាហរណ៍-ដោយសារទីផ្សារដំណើរការមិនល្អ ឬមិនមានការប្រកួតប្រជែងពេញលេញ។ ដូច្នេះរដ្ឋាភិបាលអាចមានហេតុផលត្រឹមត្រូវក្នុងការធ្វើអន្តរាគមន៍ ដើម្បីធ្វើឲ្យមានលទ្ធផលសេដ្ឋកិច្ចកាន់តែប្រសើរ។ បុព្វហេតុនៃបរាជ័យទីផ្សាររួមមាន៖

- ***អំណាចទីផ្សារ*** - រចនាសម្ព័ន្ធទីផ្សារមិនមានការប្រកួតប្រជែង (ផ្តាច់មុខឬស្ទើរតែផ្តាច់មុខ) និងឥរិយាបថប្រឆាំងការប្រកួតប្រជែង (ការឃុបឃិតគ្នា) អាចបណ្តាលឲ្យថ្លៃកើនឡើង ឬបណ្តាលឲ្យមានការផ្គត់ផ្គង់ទាបជាងតម្រូវការ។ រដ្ឋាភិបាលអាចអន្តរាគមន៍ដើម្បីធានាថាមិនមានការប្រើប្រាស់អំណាចទីផ្សារ ដែលធ្វើឲ្យអ្នកប្រើប្រាស់ខាតប្រយោជន៍។

- ***កត្តាសាយភាយ*** - វាកើតឡើងនៅពេលសកម្មភាពមួយដាក់បន្ទុកចំណាយ (មិនបានទូទាត់សងវិញ) ឬបង្កើតផលចំណេញ (មិនចែករំលែក) ដល់អ្នកពាក់ព័ន្ធផ្សេងទៀត។ កត្តាសាយភាយអាចធ្វើឲ្យសកម្មភាពមួយអាចកើតឡើងច្រើនហួសឬតិចពេក។ រដ្ឋាភិបាលអាចអន្តរាគមន៍ ដើម្បីធានាឲ្យមានការយកចិត្តទុកដាក់លើការដាក់បន្ទុកចំណាយនិងផលចំណេញទាំងនោះ។

- ***ព័ត៌មានមិនគ្រប់គ្រាន់*** - ដើម្បីសម្រេចឲ្យបានត្រឹមត្រូវ អ្នកប្រើប្រាស់ត្រូវមានព័ត៌មានអំពីគុណភាពឬហានិភ័យរបស់ផលិតផល។ រដ្ឋាភិបាលអាចអន្តរាគមន៍ ដើម្បីធានាថាអ្នកលក់ត្រូវតែបង្ហាញព័ត៌មានសំខាន់ៗដល់អ្នកប្រើប្រាស់។

- ***ទំនិញសាធារណៈ*** - គឺជាទំនិញឬសេវាដែលប្រើប្រាស់ដោយអ្នកខ្លះមិនត្រូវបានគេកាត់បន្ថយចំនួនសម្រាប់អ្នកប្រើប្រាស់ដទៃទៀត (មិនប្រកួតប្រជែង) និងគ្មាននរណាអាចរារាំងការប្រើប្រាស់បានទេ (មិនហាមឃាត់)។ ទំនិញសាធារណៈទាំងនោះអាចផ្គត់ផ្គង់មិនបានគ្រប់គ្រាន់ ប្រសិនបើគ្មានកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាល។

## ហេតុអ្វីបានជាលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់មិនគ្រប់គ្រាន់?

សារៈសំខាន់នៃការកំណត់បញ្ហាដែលបានកើតឡើង គឺត្រូវពិនិត្យលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ និងបង្ហាញថាលិខិតបទដ្ឋានគតិយុត្តទាំងនោះមិនអាចដោះស្រាយបញ្ហាបាន។ ការពិនិត្យនេះធានាថា បញ្ញត្តិកម្មថ្មីនឹងបង្កើតឡើងនៅពេលដែលចាំបាច់។ របៀបនេះ នាំមកនូវការសម្របសម្រួលច្រើន ចំពោះដំណើរការតាក់តែងបញ្ញត្តិកម្មរបស់ក្រសួងស្ថាប័ននានា។

ការពិចារណាដោយប្រុងប្រយ័ត្នលើបញ្ញត្តិកម្មដែលមានស្រាប់អាចជួយកំណត់ជម្រើសផ្សេងៗផងដែរ។ ការកែលម្អការតាក់តែងអនុវត្តបញ្ញត្តិកម្មដែលមានស្រាប់នោះ អាចដោះស្រាយបញ្ហាបានដោយចំណាយតិចជាងការបង្កើតបញ្ញត្តិកម្មថ្មី។

## ការផ្តល់ភស្តុតាងចំពោះបញ្ហា

ការកំណត់បញ្ហាគឺមិនគ្រប់គ្រាន់ទេសម្រាប់ធាតុទី១នៃRIA។ ការផ្តល់ភស្តុតាងចំពោះបញ្ហាដែលបានកើតឡើងមានសារៈសំខាន់។

ភស្តុតាងអាចផ្តល់ក្នុងទម្រង់ជាស្ថិតិករណីសិក្សាឬឧទាហរណ៍ដោយផ្អែកលើទំហំនិងផលវិបាកនៃបញ្ហា។ ប្រសិនបើបញ្ហាកាន់តែសំខាន់ ត្រូវមានទិន្នន័យកាន់តែរឹងមាំ។

ស្ថិតិអំពីទំហំនៃបញ្ហា - ប្រមូលដោយរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ឬអ្នកពាក់ព័ន្ធ / អ្នកស្រាវជ្រាវផ្សេងទៀត - គឺជាទម្រង់នៃភស្តុតាងរឹងមាំ។

ទោះបីជាយើងត្រូវការភស្តុតាងទាំងនេះក៏ដោយ ក៏ភស្តុតាងទាំងនេះពិបាករក ឬត្រូវចំណាយច្រើនដែរ។ ក្នុងករណីនេះ ការប្រើប្រាស់ករណីសិក្សា អាចទទួលយកបានឬផ្តល់ឧទាហរណ៍មួយៗនៃបញ្ហា។

ទិន្នន័យពីប្រទេសផ្សេងដែលមានសេដ្ឋកិច្ច ភូមិសាស្ត្រ សង្គម និង/ឬវប្បធម៌ស្រដៀងគ្នានឹងប្រទេសកម្ពុជា អាចប្រើជាទិន្នន័យសម្រាប់ភស្តុតាងបឋមផងដែរ។

# ការបង្ហាញអំពីគោលបំណងនៃកិច្ចអន្តរាគមន៍

## ធាតុទី២ : គោលបំណង

ដោយបានកំណត់បញ្ហាដែលត្រូវដោះស្រាយតាមរយៈកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាល ធាតុបន្ទាប់របស់RIA គឺកំណត់គោលបំណងនៃកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាល។ ការកំណត់គោលបំណងនឹងផ្តល់នូវមូលដ្ឋានគោល ដើម្បីសាកល្បងទម្រង់ផ្សេងៗនៃកិច្ចអន្តរាគមន៍។

វាជាការសំខាន់ដែលគោលបំណងបានកំណត់ជាលទ្ធផលដែលកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាលចង់បាន និងមិនមែនជាទម្រង់នៃកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាលទេ។ ហេតុនេះតម្រូវឲ្យមានជម្រើសផ្សេងៗ ដែលត្រូវវាយតម្លៃឲ្យបានត្រឹមត្រូវ។

- ការកំណត់គោលបំណងតាមជម្រើសជាក់លាក់ណាមួយដើម្បីឲ្យសម្រេចលទ្ធផល នឹងនាំឲ្យការវិភាគលម្អៀងទៅលើជម្រើសដទៃទៀត ។

ឧទាហរណ៍ - រដ្ឋាភិបាលធ្វើអន្តរាគមន៍ជាច្រើន ដើម្បីកាត់បន្ថយការបាត់បង់ជីវិតដោយគ្រោះថ្នាក់ចរាចរណ៍ ដោយតម្រូវឲ្យអ្នកបើកបរម៉ូតូពាក់មួកសុវត្ថិភាព កំណត់ល្បឿនបើកបរ និងត្រួតពិនិត្យភ្លើងចរាចរណ៍នៅផ្លូវបំបែកជាបួន។ នៅពេលពិចារណាពីសំណើបញ្ញត្តិកម្មថ្មី ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ គោលបំណងគួរកំណត់ថា "ពង្រឹងសុវត្ថិភាពចរាចរណ៍" ឬក៏អ្វីមួយស្រដៀងគ្នា។ ប្រសិនបើកំណត់គោលបំណងដោយតម្រូវឲ្យ "ពាក់មួកសុវត្ថិភាព" ការនេះនឹងរារាំងការពិចារណាជម្រើសល្អៗជាច្រើនទៀត។

គេត្រូវជ្រើសរវាងការកំណត់គោលបំណងទូលាយពេកឬចង្អៀតពេក ៖

- គោលបំណងទូលាយពេកនឹងធ្វើឲ្យការវិភាគមិនច្បាស់លាស់ (ឧទាហរណ៍សម្រាប់សុខុមាលភាពប្រជាជន)
- គោលបំណងចង្អៀតពេកនាំឲ្យរឹតត្បិតដល់ជម្រើស។

គោលបំណងដែលបានជ្រើសរើស គួរពិចារណាលើកត្តាផ្សេងទៀត ដែលអាចផ្ទុយនឹងគោលបំណងរបស់រដ្ឋាភិបាល។ បើពុំនោះទេ កិច្ចអន្តរាគមន៍របស់រដ្ឋាភិបាលអាចលុបចោលគំនិតផ្តើមផ្សេងទៀត។ ឧទាហរណ៍ - គោលបំណងនៃកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាល ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការប្រើប្រាស់ថាមពលនៅតាមគេហដ្ឋាន គួរពិចារណាផងដែរលើលទ្ធភាពទិញគេហដ្ឋាន ប្រសិនបើវាជាគោលបំណងរបស់រដ្ឋាភិបាល។

## គោលបំណង S.M.A.R.T

គុណភាពនៃគោលបំណង និងតម្លៃដែលបានបន្ថែមដល់ការវិភាគនឹងមានភាពប្រសើរឡើង ប្រសិនបើគោលការណ៍ **S.M.A.R.T** ត្រូវបានអនុវត្ត។

### ជាក់លាក់ (SPECIFIC)

- ផ្តល់ភាពល្អិតល្អន់ ដើម្បីឲ្យការវិភាគមានន័យ។ គោលបំណងមិនច្បាស់លាស់នាំឲ្យការប្រឹងប្រែងទៅខុសទិសដៅ។ សូមប្រុងប្រយ័ត្នកុំបញ្ជាក់អំពីវិធីដែលធ្វើឲ្យសម្រេចគោលបំណងពីព្រោះវាអាចទាត់ចោលនូវជម្រើសល្អៗផ្សេងទៀត។

**អាចវាស់បាន** (MEASURABLE)

- កំណត់ចំនួនក្នុងគោលបំណង ដើម្បីជួយយើងពន្យល់អំពីលទ្ធភាពដែលអាចមាន ឬនឹងសម្រេចបាន។ ការនេះនឹងធ្វើឲ្យការប្រៀបធៀបជម្រើសផ្សេងៗកាន់តែប្រសើរឡើង ខណៈដែលវិភាគវាអាចវាស់បាន ថាតើជម្រើសនីមួយៗនៅឆ្ងាយកម្រិតណាពីគោលបំណង។

**អាចសម្រេចបាន** (ATTAINABLE)

- ភាពឥតខ្ចោះមិនអាចសម្រេចបានទាំងអស់នោះទេ។ ឧទាហរណ៍ - រដ្ឋាភិបាលមិនអាចលុបបំបាត់ហានិភ័យទាំងអស់បានទេ។ ការកំណត់គោលបំណងទៅតាមលទ្ធភាពរបស់រដ្ឋាភិបាលនឹងជួយបញ្ចៀសការអះអាងខុសអំពីផលចំណេញទៅថ្ងៃក្រោយ។

ពាក់ព័ន្ធ (RELEVANT)

- គោលបំណង គួរបន្ស៊ីទៅនឹងការទទួលខុសត្រូវនិងសមត្ថភាពរបស់ក្រសួងស្ថាប័ន។ ប្រសិនបើលើកបញ្ហាដែលត្រូវដោះស្រាយហួសពីការទទួលខុសត្រូវរបស់យើង យើងអាចពិចារណាថាតើសំណើបញ្ញត្តិកម្មនោះសមរម្យឬមិនសមស្រប។

**រយៈពេល** (TIMEFRAME)

- បញ្ជាក់ពីរយៈពេលក្នុងការធ្វើឲ្យសម្រេចគោលបំណង។ ភាពប្រសើរមិនអាចកើតឡើងក្នុងរយៈតែមួយថ្ងៃបានទេ។ ការផ្លាស់ប្តូរលឿនពេក អាចផ្តល់លទ្ធផលមិនសូវល្អ។ ការសម្រេចគោលដៅក្នុងរយៈពេលមួយសមស្រប គឺជាការល្អ។

## ឧទាហរណ៍ទី១

រដ្ឋាភិបាលអូស្ត្រាលីកំពុងបង្កើតបណ្ដាញរលកអាកាសធំជាតិ (NBN) ដើម្បីឲ្យប្រជាជនអូស្ត្រាលីភាគច្រើន ប្រើប្រាស់រលកអាកាសល្បឿនលឿនបាន។

ក្នុងករណីនេះ គោលបំណង គឺប្រជាជនអូស្ត្រាលីអាចប្រើប្រាស់អ៊ិនធឺណិតដែលមានល្បឿនលឿន។

មធ្យោបាយមួយ(ឬវិធីសាស្ត្រមួយ)ដើម្បីសម្រេចគោលបំណងនេះគឺឲ្យរដ្ឋាភិបាលសាងសង់បណ្ដាញខ្សែកាបអុបទិក។ មធ្យោបាយផ្សេងទៀត រួមមានឧបត្ថម្ភធនដល់ការតភ្ជាប់ក្នុងតំបន់ដែលមិនមែនជាការធ្វើពាណិជ្ជកម្មរបស់ក្រុមហ៊ុនឯកជនទេ។ ការតភ្ជាប់នៅក្នុងទីក្រុងសំខាន់ៗ នឹងអាចផ្ដល់ជូនជាលក្ខណៈពាណិជ្ជកម្ម។

ការកំណត់គោលបំណងដូចជាការសាងសង់បណ្ដាញរលកអាកាសជាតិ(NBN) គឺជាការសម្រេចខុសឆ្គងធម្មតាមួយ ដែលមិនអាចទទួលបាននៅក្នុងក្របខណ្ឌការងារRIA ពីព្រោះវាធ្វើឲ្យការវិភាគមានភាពលម្អៀង ធៀបនឹងជម្រើសផ្សេងទៀតដែលសម្រេចគោលបំណងដូចគ្នា។

## ឧទាហរណ៍ទី២

រដ្ឋាភិបាលចង់ដោះស្រាយបញ្ហាក្មេងពុល បន្ទាប់ពីលេបថ្នាំដែលទុកចោលនៅក្នុងផ្ទះ។

សំណើបញ្ញត្តិកម្ម ត្រូវបានតាក់តែងឡើងដើម្បីសម្រេចគោលបំណង ដោយធ្វើឲ្យដបថ្នាំពិបាកបើក។ ទោះបីជាយ៉ាងនេះក្តី នៅតែមាន

ក្មេងពុលមានចំនួនកើនឡើង បន្ទាប់ពីលេបថ្នាំដែលទុកចោលនៅក្នុងផ្ទះ ពីព្រោះមនុស្សចាស់ជាច្រើនដែលមិនអាចបើកគម្របដបថ្នាំបានគាត់ក៏ជំនួសដោយគម្របថ្មីដើម្បីងាយបើកលើកក្រោយ នៅពេលគាត់បើកវាបានម្តងហើយ។

សំណើបញ្ញត្តិកម្មត្រូវក៏បានតាក់តែងឡើងវិញ ដើម្បីសម្រេចគោលបំណងកាត់បន្ថយក្មេងៗយកថ្នាំប្រើប្រាស់បាន។ ជាមួយនឹងគោលបំណងទូលាយនេះ ដំណោះស្រាយគឺផ្សព្វផ្សាយអប់រំឪពុកម្តាយឲ្យទុកដាក់ដបថ្នាំកុំឲ្យក្មេងយកបាន ដាក់ស្លាកសញ្ញាព្រមានលើដបថ្នាំ ធ្វើដបថ្នាំឲ្យងាយបើកបានសម្រាប់តែអ្នកដែលអាចអានអក្សរបានប៉ុណ្ណោះ។ វិធានការនេះកាត់បន្ថយចំនួនក្មេងពុលបាន។

# ការជ្រើសរើសជម្រើសសម្រាប់ធ្វើការវិភាគ

## ធាតុទី៣ - ជម្រើស

ជម្រើស គឺជាវិធីដោះស្រាយដទៃទៀតដែលអាចធ្វើឲ្យសម្រេចគោលបំណងដែលបានកំណត់។ ជាទីបញ្ចប់ ជម្រើសទាំងនោះ ជាមធ្យោបាយដោះស្រាយខុសៗគ្នា ដើម្បីសម្រេចគោលបំណងតែមួយ។

រាល់ការវិភាគផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ត្រូវពិចារណាពីជម្រើសផ្សេងៗ។ ជាពិសេស ត្រូវពិចារណារកជម្រើសមិនមែនបញ្ញត្តិកម្មនិងជម្រើសមិនស្មុគស្មាញ គួរត្រូវយកមកពិចារណាជាមួយនឹងសំណើបញ្ញត្តិកម្ម។ ប្រសិនបើRIAពិចារណាតែសំណើបញ្ញត្តិកម្មនោះមិនធានាថាជ្រើសរើសបានជម្រើសដ៏ល្អប្រសើរនោះទេ។

ដើម្បីជ្រើសរើសយកជម្រើស គួរបង្កើតតារាងបញ្ជីជម្រើស។ ចំនួនជម្រើសត្រូវបានកាត់បន្ថយ ដោយដកចេញជម្រើសដែលមិនអាចអនុវត្តបាន ដូចជាជម្រើសដែលមិនអាចធ្វើបាន ឬរំលោភលើអនុសញ្ញាអន្តរជាតិជាដើម។

បន្ទាប់ពីកំណត់ចុងក្រោយនូវជម្រើស៣ទៅ៤ (ករណីខ្លះមានច្រើនជាងនេះ) ជម្រើសនីមួយៗគួរអធិប្បាយឲ្យបានលម្អិតល្មម ដើម្បីឲ្យអ្នកពាក់ព័ន្ធយល់អំពីអ្វីដែលបានស្នើ និងធ្វើការប្រៀបធៀបជម្រើសទាំងនោះនៅក្នុងផ្នែកវិភាគផលប៉ះពាល់។

ព័ត៌មានបន្ថែមអំពីជម្រើសផ្សេងៗដែលអ្នកអាចពិចារណា មាននៅក្នុងការវិភាគរបស់អ្នក។

## ការណែនាំ - តើការជ្រើសរើសជម្រើសរបស់អ្នកត្រឹមត្រូវឬទេ?

ជម្រើសទាំងអស់ ត្រូវតែអនុវត្តបាននៅក្នុងក្របខណ្ឌលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ អនុសញ្ញាអន្តរជាតិ រចនាសម្ព័ន្ធសង្គម និងវប្បធម៌។

ជម្រើសមិនមែនបញ្ញត្តិកម្ម គួរពិចារណានៅរាល់ការអនុវត្តRIA លើកលែងតែជម្រើសនោះមិនអាចធ្វើអនុវត្តបាន។

ជម្រើសនីមួយៗគួរអធិប្បាយឲ្យបានលម្អិតល្អម ដើម្បីឲ្យអ្នកពាក់ព័ន្ធអាចយល់នូវអ្វីដែលបានស្នើ និងធ្វើការប្រៀបធៀបជម្រើសទាំងនោះ នៅក្នុងផ្នែកវិភាគផលប៉ះពាល់។

## ឧទាហរណ៍នៃជម្រើសជាបញ្ញត្តិកម្ម និងជម្រើសមិនមែនជាបញ្ញត្តិកម្ម

ជម្រើសមិនមែនជាបញ្ញត្តិកម្ម ៖

- ព័ត៌មានសាធារណៈនិងយុទ្ធនាការអប់រំ – ប្រសិទ្ធភាពនៃយុទ្ធនាការអប់រំអាចសម្រេចគោលបំណងដោយគ្មានការចាប់បង្ខំតាមរយៈបញ្ញត្តិកម្ម
- ការផ្តល់រង្វាន់ដល់ការផ្លាស់ឥរិយាបថល្អ។

**ឧបករណ៍ទីផ្សារ**

- សិទ្ធិធ្វើពាណិជ្ជកម្ម (ឧទាហរណ៍ សិទ្ធិធ្វើពាណិជ្ជកម្មទឹក)
- ពន្ធនិងឧបត្ថម្ភធន (ឧទាហរណ៍ដាក់ពន្ធលើភេសជ្ជៈស្រវឹងនិងថ្នាំជក់)។

**ការកែលម្អលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់**

- ពង្រឹងការអនុវត្តបទបញ្ញត្តិដែលមានស្រាប់

- ពង្រីកវិសាលភាពនៃលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់។

## បញ្ញត្តិកម្មមានកម្រិតស្រាល

- **ស្វ័យគ្រប់គ្រង** – ក្រុមហ៊ុនឯកភាពគ្នាលើគោលការណ៍មួយចំនួន ដែលពួកគេស្ម័គ្រចិត្តអនុវត្ត (ករណីនេះ អាចមានប្រសិទ្ធភាពនៅពេលហានិភ័យទាប និងឧស្សាហកម្មមានការប្រមូលផ្តុំ ដោយមានការទទួលខុសត្រូវ និងសមាគមឧស្សាហកម្មមានឥទ្ធិពល)។
- **សហបញ្ញត្តិកម្ម** – នៅពេលរដ្ឋាភិបាលនិងឧស្សាហកម្មសហការគ្នាក្នុងការតាក់តែងនិងពង្រឹងការអនុវត្តច្បាប់។ យើងប្រើប្រាស់ជម្រើសនេះនៅពេលជំនាញបច្ចេកទេសមានសារៈសំខាន់។
- **បញ្ញត្តិកម្មវិជ្ជមាន** – ការទទួលស្គាល់គុណភាពទំនិញឬសេវាល្អឥរិយាបថល្អ ការគ្រប់គ្រងល្អរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនទទួលបានបណ្ណសរសើរដែលមានកិត្តិនាមនៅក្នុងទីផ្សារ។
- **អាជ្ញាបណ្ណអវិជ្ជមាន** – ការព្រមានដកអាជ្ញាបណ្ណពីក្រុមហ៊ុនឬបុគ្គលដែលបានទទួលអាជ្ញាបណ្ណធ្វើអ្វីមួយ ដោយមិនបានបំពេញតាមលក្ខខណ្ឌកំណត់។
- **បញ្ញត្តិកម្មផ្អែកលើហានិភ័យ** – តម្រូវការបញ្ញត្តិកម្មនឹងប្រែប្រួលទៅតាមហានិភ័យនៃសកម្មភាពដែលបានដាក់បញ្ញត្តិ។ សកម្មភាពទាំងឡាយដែលបង្កើតហានិភ័យ ដោយមានផលវិបាកតិចតួចកើតឡើង គេអាចដាក់បញ្ញត្តិកាន់តែស្រាល។

# ការពិចារណាលើបន្ទុកចំណាយ និងផលចំណេញ

## ធាតុទី ៤- ការវិភាគផលប៉ះពាល់

បញ្ញត្តិកម្មតម្រូវឲ្យមានបន្ទុកចំណាយចំពោះរដ្ឋាភិបាល ធុរកិច្ច និងបុគ្គល។ បញ្ញត្តិកម្មដែលមានប្រសិទ្ធភាព នឹងផ្តល់នូវផលចំណេញ នៅពេលណាដែលគោលបំណងរបស់រដ្ឋាភិបាលត្រូវបានសម្រេច។

ការវិភាគផលប៉ះពាល់ផ្តល់ជូនថ្នាក់ដឹកនាំ នូវព័ត៌មានគ្រប់គ្រាន់ ក្នុងការថ្លឹងថ្លែងអំពីផលប៉ះពាល់វិជ្ជមាននិងអវិជ្ជមាន។ ប្រសិនបើ ថ្នាក់ដឹកនាំសម្រេចជ្រើសរើសការធ្វើបញ្ញត្តិកម្ម ដោយមិនមានការ វិភាគពីផលប៉ះពាល់ នោះគោលបំណងមិនអាចសម្រេចបាន ឬជម្រើស ដែលមានបន្ទុកចំណាយតិចនឹងត្រូវមើលរំលង។ ដូច្នេះ តួនាទីរបស់ការ វិភាគផលប៉ះពាល់គឺជួយថ្នាក់ដឹកនាំឲ្យចៀសវាងបាននូវកំហុសខាង លើនេះ ។

ការវាយតម្លៃផលប៉ះពាល់ ត្រូវមានរូបភាពច្បាស់លាស់អំពី ដំណើរការរបស់បញ្ញត្តិកម្ម ដែលមិនបានពន្យល់លម្អិតនៅក្នុងសេចក្តី ព្រាងបញ្ញត្តិកម្ម។ ឧទាហរណ៍ - បញ្ញត្តិកម្មមួយអាចហាមឃាត់ការ ប្រើប្រាស់ជ័រការ ដែលមានជាតិពុលសម្រាប់ការផលិតស្បែកជើងនៅ កម្ពុជា។ ក៏ប៉ុន្តែបញ្ញត្តិកម្មនេះនឹងមិនចែងអំពី៖

- ជ័រការជំនួស ឬដំណើរការផលិតស្បែកជើង
- តើអ្នកផលិតត្រូវធ្វើយ៉ាងណា ដើម្បីបង្ហាញថាពួកគាត់បាន អនុវត្តតាមការហាមឃាត់នោះ
- តើរដ្ឋាភិបាលនឹងអះអាងដោយរបៀបណាដែលថាតើករណី ខាងលើនេះជាបញ្ហាដែលត្រូវដោះស្រាយ។

គោលបំណងនៃបញ្ញត្តិកម្មខាងលើនេះ គឺដើម្បីការពារកម្មករពីការដួលសន្លប់ ប៉ុន្តែបញ្ញត្តិកម្មនេះនឹងមិនមានប្រសិទ្ធភាពទេ ប្រសិនបើជ័រការដែលជំនួសនោះនៅតែមានជាតិពុល ឬក៏ការហាមឃាត់នេះធ្វើឲ្យមានចំណាយខ្ពស់ក្នុងការផលិតស្បែកជើង។

ការវិភាគផលប៉ះពាល់មានតួនាទីដើម្បី៖

- កំណត់អត្តសញ្ញាណនៃការផ្លាស់ប្តូរឥរិយាបថ ដែលបណ្តាលមកពីជម្រើសនីមួយៗ
- បង្ហាញជាបរិមាណជាមួយនឹងភាពញឹកញាប់នៃការកើតមានការផ្លាស់ប្តូរទាំងនេះ
- កំណត់បន្ទុកចំណាយ(ឬផលចំណេញ) នៃការផ្លាស់ប្តូរនីមួយៗទាំងនេះ។

## ការវិភាគផលប៉ះពាល់អាចមានទម្រង់ច្រើន

RIAជារឿយៗត្រូវបានគេចាត់ទុកជាមធ្យោបាយដើម្បីធានាថាមានតែបញ្ញត្តិកម្មដែលលើកកម្ពស់សុខុមាលភាពសង្គមប៉ុណ្ណោះ ដែលត្រូវបានយកមកអនុវត្ត ដោយប្រើប្រាស់ទម្រង់បញ្ញត្តិកម្មដែលមានប្រសិទ្ធភាពបំផុត។ RIAប្រើប្រាស់ឧបករណ៍វិភាគបន្ទុកចំណាយនិងផលចំណេញ(CBA)ដើម្បីបង្ហាញថា តើជម្រើសណាមួយផ្តល់ផលចំណេញច្រើនជាងបន្ទុកចំណាយ និងជម្រើសណាមួយដែលសម្រេចបានផលចំណេញតាមកំណត់ឲ្យមានបន្ទុកចំណាយតិច។

ក្នុងប្រព័ន្ធRIA មានការប្រើប្រាស់ការវិភាពតាមបែបCBAតិចតួចណាស់។ ការតម្រូវឲ្យបានស្តង់ដាវិភាគបែបនេះសម្រាប់កម្ពុជា ធ្វើឲ្យមានការលំបាកក្នុងការធ្វើPASឬRIS នាំឲ្យការបញ្ចប់PASឬRIS

បានតែមួយចំនួនតូចប៉ុណ្ណោះ។ ដូច្នេះ គោលការណ៍ណែនាំនេះជំរុញឲ្យមានការវិភាគផលប៉ះពាល់ ដែលមានគោលបំណងផ្តល់ព័ត៌មានគ្រប់គ្រាន់ជូន ថ្នាក់ដឹកនាំដោយមានការប្រៀបធៀបជម្រើសនីមួយៗ។

**ការកំណត់**អំពីបន្ទុកចំណាយ និងផលចំណេញនៃបញ្ញត្តិកម្មជួយឲ្យថ្នាក់ដឹកនាំយល់ដឹងពេញលេញ អំពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានដែលបញ្ញត្តិកម្មអាចបង្កឡើង។

ជារឿយៗ ប្រសិទ្ធភាពនៃបញ្ញត្តិកម្មត្រូវបានគេរំពឹងទុកខ្ពស់ពេក។ ដូច្នេះ ទិន្នន័យស្តីពីវិសាលភាពនៃបញ្ហានិងជម្រើសនីមួយៗ ដែលឆ្លើយតបនឹងបញ្ហា មានសារប្រយោជន៍ណាស់។ ជាទូទៅ ការអនុវត្តតាមបញ្ញត្តិកម្មជាធម្មតាមានពាក់ព័ន្ធទៅនឹងសកម្មភាពញឹកញាប់ច្រើនជាងការរំពឹងទុក (ឧ. ការតាមដានត្រួតពិនិត្យ)។ **ការកំណត់ពីបរិមាណ**នៃប្រសិទ្ធភាពរបស់ជម្រើសនិងបន្ទុកចំណាយ នឹងជួយឲ្យថ្នាក់ដឹកនាំអាចថ្លឹងថ្លែងបានល្អរវាងផលប៉ះពាល់វិជ្ជមាននិងអវិជ្ជមាននៃជម្រើសផ្សេងៗ។

**ការកំណត់តម្លៃ**បន្ទុកចំណាយ បានត្រឹមតែអនុញ្ញាតឲ្យថ្នាក់ដឹកនាំធ្វើការជ្រើសរើសជម្រើសនីមួយៗ ដោយផ្អែកលើប្រសិទ្ធភាពបន្ទុកចំណាយប៉ុណ្ណោះ។ យ៉ាងល្អវិសេស បន្ទុកចំណាយនិងផលចំណេញត្រូវបានគណនាជាតម្លៃ ដោយប្រើរង្វាស់សាមញ្ញតែមួយ ដូចជាដុល្លារជាដើម។ យ៉ាងណាមិញ ការគណនាផលចំណេញជារង្វាស់សាមញ្ញនោះមិនអាចធ្វើទៅបានជានិច្ចនៅគ្រប់កាលៈទេសៈនោះទេ។ នៅពេលដែលការគណនាជារូបិយវត្ថុមិនអាចធ្វើទៅបាន គេអាច

ប្រើប្រាស់ការកំណត់តម្លៃតាមបែបគុណភាព ឬតាមបែបអត្ថនោម័ត ដើម្បីប្រៀបធៀបជម្រើសនីមួយៗ។

## ការកំណត់អំពីបន្ទុកចំណាយរបស់បញ្ញត្តិកម្ម

ការអនុវត្តតាម(និងការពង្រឹងការអនុវត្ត)បញ្ញត្តិកម្មណាមួយត្រូវប្រើប្រាស់ធនធាន ដែលអាចយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងទៀត។ **តម្លៃឱកាស**នៃបញ្ញត្តិកម្ម គឺជាការបាត់បង់ធនធានដែលអាចប្រើធនធាននោះសម្រាប់គោលបំណងផ្សេង។ **តម្លៃឱកាស**នៃធនធាន គឺអាចវាស់តាមតម្លៃវាបានក្នុងពេលប្រើប្រាស់ជំនួសប្រសើរបំផុត។

ដំណាក់កាលដំបូងនៃការវិភាគផលប៉ះពាល់ គឺដើម្បីកំណត់ថាភាគីទាំងអស់នឹងផ្លាស់ប្តូរឥរិយាបថរបស់ពួកគេ ប្រសិនបើជម្រើសនីមួយៗត្រូវបានអនុវត្ត និងដើម្បីពណ៌នាអំពី**តម្លៃឱកាស**នៃការផ្លាស់ប្តូរឥរិយាបថទាំងនេះ។

ធុរកិច្ច រដ្ឋាភិបាល និងបុគ្គលម្នាក់ៗ ទាំងអស់គ្នាមិនបានគិតគូរដល់ពេលវេលានិងប្រាក់ដែលអាចដាក់ឲ្យប្រើប្រាស់ជទៃផ្សេងទៀត នៅពេលដែលគេប្រតិបត្តិតាម គេពង្រឹងការអនុវត្តបញ្ញត្តិកម្ម ឬបើមិនដូច្នោះទេ គេនឹងទទួលផលប៉ះពាល់ដោយបញ្ញត្តិកម្ម។ ឧទាហរណ៍នៃ**តម្លៃឱកាស**មានដូចខាងក្រោម៖

**សម្រាប់អ្នកប្រតិបត្តិតាមបញ្ញត្តិកម្ម :**

- ពេលវេលា ដើម្បីបំពេញការងាររដ្ឋបាល និងដើម្បីការរង់ចាំ
- ប្រាក់ត្រូវចំណាយដើម្បីអនុវត្តតាមបញ្ញត្តិកម្ម និងការបង់កម្រៃផ្សេងៗ។

**សម្រាប់បញ្ញត្តិករ :**

- ពេលវេលា និងប្រាក់ ដើម្បីពង្រឹងនិងអនុវត្ត

**សម្រាប់តតិយជន (អតិថិជន, អ្នកប្រកួតប្រជែង, អ្នកផ្គត់ផ្គង់) :**

- ពេលវេលា ប្រាក់ និងការបាត់បង់ឱកាស ដូចជាការកាត់បន្ថយភាពងាយស្រួលផ្សេងៗ តម្លៃ ឬគុណភាពសេវាកម្មទៅលើការផ្គត់ផ្គង់។

ក្រសួងឬនាយកដ្ឋានដែលបានរៀបចំសេចក្តីព្រាងបញ្ញត្តិកម្ម អាចមិនដឹងពីផលប៉ះពាល់ជាច្រើន នៅក្នុងដំណាក់កាលដំបូងនៃការវិភាគផលប៉ះពាល់ក្នុងការធ្វើPAS។ ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនឹងជួយធានាថា រាល់បន្ទុកចំណាយទាំងអស់ត្រូវបានកំណត់ ក៏ដូចជាឲ្យពួកគេនឹងបានយល់ដឹងកាន់តែច្បាស់អំពីបញ្ញត្តិកម្មដែលនឹងផ្លាស់ប្តូរឥរិយាបថពួកគេយ៉ាងណានោះ។

## ការកំណត់ពីផលចំណេញ

ផលចំណេញរបស់បញ្ញត្តិកម្ម គឺឆ្លុះបញ្ចាំងអំពីការធ្វើឲ្យប្រសើរឡើងនូវសុខុមាលភាពរបស់មនុស្ស ដើម្បីចៀសវាងនូវការខូចខាតឬការបាត់បង់សុខុមាលភាពរបស់មនុស្សដោយសារតែមិនមានបញ្ញត្តិកម្ម។

ជាធម្មតា ផលចំណេញចម្បងរបស់បញ្ញត្តិកម្មនិងជម្រើសដទៃទៀត ដែលបានវិភាគនៅក្នុងRIA គឺងាយស្រួលក្នុងការកំណត់និងសង្ឃឹមថាអាចសម្រេចបាន ដូចជាការកាត់បន្ថយការស្លាប់ដោយគ្រោះថ្នាក់ ការការពារបរិស្ថានឬការការពារអ្នកប្រើប្រាស់។

ប្រសិនបើផលចំណេញចម្បងរបស់បញ្ញត្តិកម្មមិនសម្រេចបានតាមគោលបំណងដែលបានជ្រើសរើសទេ យើងត្រូវគិតពិចារណាឡើងវិញថាជម្រើសនោះត្រឹមត្រូវឬមិនត្រឹមត្រូវ។ ទោះបីជាយ៉ាងណាក៏ដោយ ផលចំណេញរបស់បញ្ញត្តិកម្មនិងជម្រើសដទៃទៀតមិនត្រូវកម្រិតត្រឹមតែគោលបំណងនោះទេ។ ឧទាហរណ៍ : សកម្មភាពរបស់រដ្ឋាភិបាលដើម្បីកែលម្អឧបករណ៍អគ្គិសនីការពារបរិស្ថាន អាចផ្តល់ផលចំណេញដល់អ្នកប្រើប្រាស់ ដោយកាត់បន្ថយចំណាយទៅលើថាមពលអគ្គិសនី។

## ឧទាហរណ៍- ហេតុអ្វីបានជាការធ្វើបញ្ញត្តិកម្មមិនមែនជាផលប៉ះពាល់វិជ្ជមានឬផលចំណេញ?

រាជរដ្ឋាភិបាលកម្ពុជាតម្រូវឲ្យធុរកិច្ចចុះបញ្ជីផលិតផលដែលខ្លួនលក់ ដូច្នេះការចុះបញ្ជីផលិតផលនេះ គឺមិនមែនជាផលចំណេញរបស់ធុរជនទេ។

ទោះបីជាដូច្នេះក៏ដោយ ការចុះបញ្ជីនេះជួយឲ្យរដ្ឋាភិបាលតាមដានមើលថា តើក្រុមហ៊ុនណាដែលបានអនុញ្ញាតឲ្យផលិតទំនិញមានម៉ាកពាណិជ្ជត្រឹមត្រូវ ហើយក៏ជួយរដ្ឋាភិបាលក្នុងការត្រួតពិនិត្យនិងទប់ស្កាត់នូវការក្លែងបន្លំ។

ការទប់ស្កាត់ការក្លែងបន្លំមានទាំងបន្ទុកចំណាយនិងផលចំណេញសម្រាប់ប្រទេសកម្ពុជា ដែលអាចធ្វើឲ្យថ្លៃទំនិញខ្ពស់សម្រាប់អ្នកប្រើប្រាស់ ប៉ុន្តែវានឹងជួយទាក់ទាញការវិនិយោគនៅក្នុងប្រទេស។

ទោះបីជាយ៉ាងនេះក្តី ក្រុមហ៊ុនអន្តរជាតិដែលមានឈ្មោះផលិតផលល្បីៗ បានមកបង្កើតរោងចក្រនៅកម្ពុជាកាន់តែច្រើនឡើងៗ ដោយពួកគេជឿជាក់ថា កម្មសិទ្ធិបញ្ញារបស់ពួកគេនឹងត្រូវបានការពារដោយ

រដ្ឋាភិបាល។ នេះគឺជាការវិនិយោគមួយ និងជាផលចំណេញនៃការចុះបញ្ជីផលិតផល ហើយព័ត៌មានដែលទទួលបានពីការចុះបញ្ជីនេះអាចមានប្រយោជន៍សម្រាប់រដ្ឋាភិបាលនិងភាគីដែលពាក់ព័ន្ធផងដែរ។

## ការកំណត់ជាបរិមាណនៃបន្ទុកចំណាយ និងផលចំណេញ

ដំណាក់កាលទី២នៃការវិភាគផលប៉ះពាល់ គឺការកំណត់ជាបរិមាណ(ឬការវាស់វែង)បន្ទុកចំណាយ និងការកំណត់ផលចំណេញរបស់ជម្រើសនីមួយៗ។ ឧទាហរណ៍ : ១-ចំនួនពាក្យសុំដែលនឹងត្រូវបំពេញ(គឺបន្ទុកចំណាយ)។ ២-ចំនួនជីវិតដែលត្រូវបានជួយសង្គ្រោះ (គឺផលចំណេញ)។

វាមានសារៈសំខាន់ណាស់ ដើម្បីធ្វើការបែងចែកនៅក្នុងដំណាក់កាលនេះ (ការកំណត់បរិមាណ) អំពីការកំណត់តម្លៃបន្ទុកចំណាយនិងផលចំណេញ (ជារូបិយវត្ថុ)។ ការកំណត់បរិមាណនៃបន្ទុកចំណាយនិងផលចំណេញអាចផ្តល់ជាព័ត៌មានដ៏មានប្រយោជន៍។ ឧទាហរណ៍ : ព័ត៌មានដែលនឹងមានប្រយោជន៍ចំពោះថ្នាក់ដឹកនាំ គឺរវាងជម្រើសមួយសង្ឃឹមថាអាចជួយសង្គ្រោះជីវិតបាន១០នាក់ និងនៅពេលដែលជម្រើសមួយទៀតអាចជួយជីវិតបានតែម្នាក់ប៉ុណ្ណោះ។ នៅក្នុងការប្រៀបធៀបការកំណត់ជារូបិយវត្ថុមានការលំបាក និងជារឿយៗមានការខ្វែងគំនិតគ្នាទៀតផង ឧទាហរណ៍ដូចជាការកំណត់តម្លៃជាផលចំណេញទាក់ទងនឹងបរិស្ថាន។

ការកំណត់បន្ទុកចំណាយនិងផលចំណេញគឺជាដំណាក់កាលសំខាន់បំផុតដើម្បីធ្វើការប្រៀបធៀបជម្រើសនានា។ គួរចងចាំថាជម្រើសទាំងអស់ ត្រូវបានជ្រើសរើសឡើងដើម្បីសម្រេចនូវលទ្ធផល

ដូចគ្នា(ឬផលចំណេញ) និងបន្ទុកចំណាយដូចគ្នា។ តម្លៃមួយឯកតានៃផលចំណេញឬមួយឯកតានៃបន្ទុកចំណាយ នឹងមានតម្លៃស្មើគ្នាសម្រាប់ជម្រើសនីមួយៗ។ ដូច្នេះ ការកំណត់បរិមាណថាជម្រើសនីមួយៗមានជោគជ័យ/ប្រសិទ្ធភាព និងការកំណត់ភាពញឹកញាប់នៃជម្រើសនីមួយៗដែលនឹងដាក់បន្ទុកចំណាយ គឺដូចជាការកំណត់ពីចំណាត់ថ្នាក់នៃជម្រើសដែរ។

គោលបំណងនៃដំណាក់កាលនេះ គឺដើម្បីប្រៀបធៀបព័ត៌មានស្ដីពីផលប៉ះពាល់នៃជម្រើសនីមួយៗ។ បើដូច្នេះ តើអ្វីជាឥទ្ធិពលនៃការទទួលយកជម្រើសនីមួយៗ(តើអ្វីត្រូវធ្វើឬផ្លាស់ប្ដូរ)។ ផលប៉ះពាល់ទាំងនេះត្រូវវាស់វែងបានដូចជាភាពខុសៗគ្នា រវាងស្ថានភាពដើមគ្មានសកម្មភាព និងស្ថានភាពដែលសង្ឃឹមថាមានអ្វីកើតមានឡើងនៅពេលដែលបញ្ញត្តិកម្មត្រូវបានអនុលោមតាម។ បើអនុវត្តបែបនេះ យើងត្រូវទទួលស្គាល់ថា បញ្ញត្តិកម្ម(និងជម្រើសដទៃទៀត)កម្រនឹងអនុវត្តបានល្អឥតខ្ចោះណាស់ ដូច្នេះ ប្រសិទ្ធភាពរបស់វាត្រូវការឲ្យមានការកំណត់ជាក់លាក់ ជាជាងយើងសន្មតថាអនុវត្តបានមួយរយភាគរយ។

## ការបង្កើតស្ថានភាពដើម

RIAពាក់ព័ន្ធនឹងការវាយតម្លៃជម្រើសជាគោលនយោបាយមួយឬច្រើន ជាមួយអ្វីដែលនឹងកើតមានឡើងក្នុងពេលគ្មានសំណើបញ្ញត្តិកម្ម នោះគឺស្ថានភាពដើម។

ការបង្កើតកម្រិតនៃបន្ទុកចំណាយនិងផលចំណេញនៅក្នុងស្ថានភាពដើម គឺមានសារៈសំខាន់ណាស់។ គេត្រូវកាត់បន្ទុកចំណាយ

និងផលចំណេញទាំងនោះ ចេញពីបន្ទុកចំណាយនិងផលចំណេញនៃជម្រើសនីមួយៗ បើពុំនោះទេ គេនឹងសន្មតខុសអំពីបន្ទុកចំណាយនិងផលចំណេញនៃជម្រើសទាំងនោះ ដោយធ្វើការរាប់បញ្ចូលទាំងបន្ទុកចំណាយនិងផលចំណេញដែលមានស្រាប់ក្នុងស្ថានភាពដើម ដែលបន្ទុកចំណាយនិងផលចំណេញទាំងនេះពុំមែនជាលទ្ធផលនៃអន្តរាគមន៍របស់ជម្រើសនីមួយៗទេ។

ឧទាហរណ៍ : ចូរពិចារណាលើបញ្ញត្តិកម្មដែលកំណត់ឲ្យពាក់អាវសុវត្ថិភាពការពារជីវិតនៅលើទូក ដើម្បីកាត់បន្ថយការស្លាប់ដោយលង់ទឹក។ ម្ចាស់ទូកឬអ្នកប្រើប្រាស់ទូកជាច្រើន បានពាក់អាវសុវត្ថិភាពការពារជីវិតនេះដោយស្ម័គ្រចិត្តរួចហើយ។ ដូច្នេះ ពួកគេនឹងមិនលង់ទឹកស្លាប់ក្នុងគ្រោះថ្នាក់របៀបនេះទេ។ ការបញ្ចូលបន្ទុកចំណាយទៅក្នុងអាវសុវត្ថិភាពនេះ គឺជាការបំប៉ោងបន្ទុកចំណាយ ហើយការបញ្ចូលវាទៅក្នុងការជួយសង្គ្រោះជីវិតក៏ជាការបំប៉ោងផលចំណេញផងដែរ។

ស្ថានភាពដើមត្រូវបានកំណត់ដោយគ្រប់បញ្ញត្តិកម្មដែលមានស្រាប់ រួមទាំងបទដ្ឋានសង្គមនិងវប្បធម៌ ដែលមានឥទ្ធិពលលើឥរិយាបថរបស់មនុស្ស ដែលទទួលរងផលប៉ះពាល់ដោយសំណើបញ្ញត្តិកម្ម។ ការលើកឡើងអំពីអាវសុវត្ថិភាពការពារជីវិត វារួមបញ្ចូលនូវការព្រួយបារម្ភរបស់ឪពុកម្តាយចំពោះកូន សុវត្ថិភាពរបស់បុគ្គលិក ឬបទបញ្ជារបស់ក្លឹបកម្សាន្តតាមទូក។ ដោយឈរលើមូលដ្ឋានច្បាប់ដែលមានស្រាប់និងឥរិយាបថ ការប៉ាន់ស្មានអំពីកម្រិតដែលមានស្រាប់ ឬការអនុវត្តតាមដោយស្ម័គ្រចិត្ត ដែលបង្កើតបានជាស្ថានភាពដើមសម្រាប់ការគណនាបន្ទុកចំណាយ។

ស្ថានភាពដើម សម្រាប់ផលចំណេញគួរត្រូវបានបង្កើតឡើង នៅពេលដែលយើងកំណត់បញ្ហា។ ក្នុងឧទាហរណ៍ខាងលើ ទំហំនៃបញ្ហាគឺចំនួនអ្នកស្លាប់ដោយសារលង់ទឹកដែលបានកើតឡើង នៅពេលដែលមនុស្សធ្លាក់ចេញពីទូក។ ការពាក់អាវសុវត្ថិភាពការពាជីវិតដោយស្ម័គ្រចិត្ត បានកាត់បន្ថយរួចហើយនូវទំហំនៃបញ្ហានេះ។ សកម្មភាពរបស់រដ្ឋាភិបាលដែលបានស្នើឡើងគ្រាន់តែបានបន្ថែម នូវការកាត់បន្ថយគ្រោះថ្នាក់ប៉ុណ្ណោះ ប៉ុន្តែវាមិនបានជួយសង្គ្រោះជីវិតមនុស្សដែលបានពាក់អាវសុវត្ថិភាពដោយស្ម័គ្រចិត្ត រួចហើយនោះទេ។

## ប្រសិទ្ធភាព

កំហុសជាទូទៅក្នុងការធ្វើបញ្ញត្តិកម្ម គឺការសន្មតថា មានតែបញ្ញត្តិកម្មទេដែលនឹងត្រូវឆ្លើយតបជាមួយបញ្ហាដែលបានកំណត់។ កំហុសនេះកើតឡើងដោយមូលហេតុពីរយ៉ាង ៖

- បញ្ញត្តិកម្មមិនល្អឥតខ្ចោះនោះទេ - វាអាចជួយកាត់បន្ថយហានិភ័យចំពោះបញ្ហាដែលកើតមានឡើង ប៉ុន្តែវាមិនអាចលុបបំបាត់បញ្ហាទាំងអស់បានទេ ដោយសារតែហានិភ័យដែលយើងមិនអាចគ្រប់គ្រងបាន ការមិនអនុវត្តតាម ឬកត្តាដទៃទៀត។
- ជារឿយៗជម្រើសដទៃទៀត ក៏អាចយកមកអនុវត្តដូចបញ្ញត្តិកម្មដែរ ប៉ុន្តែជម្រើសទាំងនោះមិនត្រូវបានយកមកពិចារណាឲ្យបានទូលំទូលាយ ដោយសារតែបានសម្រេចធ្វើបញ្ញត្តិកម្មនោះរួចហើយ។

ការកំណត់ជាបរិមាណនូវឥទ្ធិពលនៃជម្រើសនីមួយៗ អាចជួយបង្ការនូវកំហុសឆ្គងទាំងនេះ និងបានផ្តល់ព័ត៌មានដ៏ប្រសើរជូនថ្នាក់ដឹកនាំ។

PASឬRIS នឹងផ្តល់ឲ្យជូនថ្នាក់ដឹកនាំនូវព័ត៌មានគ្រប់គ្រាន់ថាតើជម្រើសនីមួយៗឆ្លើយតបជាមួយបញ្ហារបៀបណា។ ប្រសិទ្ធភាពនៃជម្រើសនីមួយៗនឹងត្រូវផ្អែកលើ ៖

- ការពង្រឹងការអនុវត្តនិងការប្រតិបត្តិតាម - ជម្រើសនឹងដោះស្រាយបញ្ហានៅពេលណាដែលជម្រើសត្រូវបានអនុវត្តប៉ុណ្ណោះ។ ដូច្នេះ ការប្រតិបត្តិតាមឲ្យបាន១០០% កម្រនឹងសម្រេចបានណាស់ ដោយសារហេតុផលជាច្រើន ដូចជាការលំបាកក្នុងការពង្រឹងការអនុវត្ត ឬវិសាលភាពមានកម្រិត (ឧ. នៅពេលដែលជម្រើសមិនបានអនុវត្តទៅលើគ្រប់ប្រជាជនទាំងអស់ដែលរងផលប៉ះពាល់ដោយសារបញ្ហា ដូចជាគម្រោងស្ម័គ្រចិត្តជាដើម)។
- តើហានិភ័យនៃបញ្ហាមានប៉ុន្មានដែលត្រូវដោះស្រាយ - សកម្មភាពនៃបញ្ញត្តិកម្ម ជាទូទៅត្រូវកំណត់ពីបុព្វហេតុជាក់លាក់នៃបញ្ហា ដូច្នេះ សូម្បីតែបុព្វហេតុទាំងនោះត្រូវបានដោះស្រាយក៏ដោយ ក៏បញ្ហានៅតែមានដដែល ដោយសារតែមានកត្តាវាដែលមិនអាចគ្រប់គ្រងបាន ដូចជាបរិស្ថានជាដើម។

ដោយសារតែPAS/RIS កំពុងវាយតម្លៃថា តើគំនិតផ្តួចផ្តើមថ្មីនឹងដំណើរការបានល្អរបៀបណានាពេលអនាគត ដូច្នេះ ព័ត៌មានស្តីពីប្រសិទ្ធភាពរបស់វាអាចមិនទាន់មាននៅឡើយ។

ការប៉ាន់ស្មានប្រសិទ្ធភាពនៃបញ្ញត្តិកម្ម អាចផ្អែកលើភស្តុតាងដែលបានមកពីការអនុវត្តបញ្ញត្តិកម្មស្រដៀងគ្នានៅបរទេស ចំណេះដឹងអំពីឧស្សាហកម្ម ក្រុមអ្នកប្រតិបត្តិតាមបញ្ញត្តិកម្ម និងការយល់ដឹងពីបុព្វហេតុនៃបញ្ហា។

- សំណើបញ្ញត្តិកម្មអាចត្រូវបានអនុវត្តរួចហើយ នៅបណ្តាប្រទេសមួយចំនួន។ ការវាយតម្លៃអំពីភាពជោគជ័យនៃបញ្ញត្តិកម្មនៅក្នុងប្រទេសទាំងនោះ អាចយកមកប្រើប្រាស់ដើម្បីប៉ាន់ស្មានតម្លៃផលប៉ះពាល់ ដែលអាចកើតមានពីសំណើបញ្ញត្តិកម្មនៅក្នុងប្រទេសកម្ពុជា។
- ឧស្សាហកម្មដែលប្រតិបត្តិតាមបានល្អ អាចរំពឹងថានឹងបន្តអនុវត្តល្អតទៅទៀត។ ដូច្នេះ ចំណេះដឹងស្តីពីឧស្សាហកម្មឬក្រុមដែលរងផលប៉ះពាល់អាចមានប្រយោជន៍សម្រាប់ប៉ាន់ស្មានតម្លៃផលប៉ះពាល់។
- បញ្ញត្តិកម្មភាគច្រើនព្យាយាមដោះស្រាយហានិភ័យដែលមានចំពោះសុខភាពមនុស្ស បរិស្ថាន។ល។ បុព្វហេតុដែលត្រូវបានដោះស្រាយ អាចមិនមែនជាបុព្វហេតុតែមួយគត់សម្រាប់ហានិភ័យទាំងនេះទេ។ ឧទាហរណ៍ - អាកាសធាតុអាចបង្កឲ្យមានហានិភ័យនៃគ្រោះថ្នាក់នៅតាមដងផ្លូវឬការបំពុលបរិស្ថាន។

បញ្ញត្តិកម្មមិនអាចគ្រប់គ្រងអាកាសធាតុបានទេ ដូច្នេះ ប្រហែលជាPAS/RISមួយចំនួនត្រូវទទួលស្គាល់ថា ហានិភ័យខ្លះនឹងនៅតែមានដដែល ទោះបីជាបញ្ញត្តិកម្មត្រូវបានអនុវត្តក៏ដោយ។

## ការសន្មត

ជារឿយៗ ភស្តុតាងអំពីមូលហេតុដើមឬប្រសិទ្ធភាពនៃជម្រើសគឺមិនអាចរកបានទេ។ ដូច្នេះ ក្រសួងអាចសន្មតការគណនាបរិមាណដើម្បីធ្វើការវិភាគ។

នៅពេលដែលមានការសន្មតរួច ហើយការសន្មតនោះគួរចែងឲ្យបានជាក់លាក់ និងគួរពន្យល់ឲ្យបានច្បាស់លាស់អំពីឥទ្ធិពលរបស់វាទៅលើលទ្ធផល (គឺថាលទ្ធផលគួរតែមានគុណភាព ដោយមានការបញ្ជាក់អំពីហានិភ័យ)។ ដូច្នេះវានឹងអាចជួយទប់ស្កាត់ថ្នាក់ដឹកនាំកុំឲ្យបកស្រាយPAS/RISខុស។

ការសន្មតគួរត្រូវបានធ្វើតេស្តសាកល្បង ដើម្បីឲ្យដឹងថាតើឥទ្ធិពលអ្វី នឹងធ្វើឲ្យមានការប្រែប្រួលទៅលើការសន្មត ដែលនឹងមានទៅលើលទ្ធផលដែលគេត្រូវតែវាយតម្លៃ។ ការសន្មតនេះ អាចទទួលបានពីការដាក់ជំនួស តម្លៃខុសៗគ្នាសម្រាប់រាល់ការសន្មត និងបានទទួលតម្លៃដែលឆ្លើយតបនឹងលទ្ធផល។

## ការកំណត់តម្លៃបន្ទុកចំណាយ និងផលចំណេញ

ដំណាក់កាលចុងក្រោយនៃការវិភាគផលប៉ះពាល់ គឺវាយតម្លៃបន្ទុកចំណាយនិងផលចំណេញ។ ការកំណត់តម្លៃជារូបិយវត្ថុ អាច

ឲ្យយើងគណនាចេញជាបន្ទុកចំណាយសរុបនិងផលចំណេញ ហើយយើងអាចប្រៀបធៀបវាជាមួយនឹងជម្រើសនានាបាន។

ជាធម្មតាបន្ទុកចំណាយផ្ទាល់នៃបញ្ញត្តិកម្ម គឺងាយស្រួលក្នុងការគណនាតម្លៃ។ ឧ. មុខទំនិញដែលបានទិញ (បន្ទុកចំណាយ) ពេលវេលាធ្វើការរបស់បុគ្គលិក (ពេលវេលាដែលបានបំពេញការងារគុណនឹងអត្រាប្រាក់ឈ្នួល) និងបន្ទុកចំណាយហិរញ្ញវត្ថុផ្ទាល់ (ដូចជាប្រាក់កម្រៃជាដើម)។

ផលចំណេញនិងបន្ទុកចំណាយមិនផ្ទាល់នៃបញ្ញត្តិកម្ម អាចមានការពិបាកក្នុងការកំណត់តម្លៃ។ សំណើបញ្ញត្តិកម្មមានគោលបំណងសំខាន់ គឺដោះស្រាយភាពបរាជ័យក្នុងទីផ្សារ ឬក៏ផលប៉ះពាល់នៃការបែងចែក។ ដូច្នេះ ការប៉ាន់ស្មានផលចំណេញជាប់ពាក់ព័ន្ធនឹងការកំណត់តម្លៃអ្វីមួយ វាមានការពិបាក ពីព្រោះតម្លៃមួយចំនួនគ្មានកំណត់ក្នុងទីផ្សារ។ ដើម្បីប៉ាន់ស្មានតម្លៃទាំងនេះ យើងមានបច្ចេកទេសជាច្រើនយកមកប្រើប្រាស់ ដូចជាវិធីសាស្ត្រឆន្ទៈក្នុងការទូទាត់ (Willingness-to-Pay)។

ការប៉ាន់ស្មានតម្លៃនៃផលចំណេញអាចធ្វើឲ្យមានបន្ទុកចំណាយ។ ប្រព័ន្ធRIAដែលមានប្រសិទ្ធភាពត្រូវតែធានាថា ការខិតខំប្រឹងប្រែងដែលចំណាយលើការវិភាគផលប៉ះពាល់ ត្រូវសមាមាត្រនឹងផលប៉ះពាល់នៃបញ្ញត្តិកម្មដែលយើងរំពឹងទុក។

សម្រាប់RIAនៅក្នុងប្រទេសកម្ពុជា យើងសង្ឃឹមថា ការប៉ាន់ស្មានភាគច្រើននៃផលចំណេញចេញមកពីការស្រាវជ្រាវដែលមាន

ស្រាប់ ឬការគណនាដែលងាយស្រួល។ ក្នុងករណីនេះ បន្ទុកចំណាយ និងផលចំណេញនៃជម្រើសនីមួយៗ ត្រូវបានគណនា (បរិមាណ x តម្លៃមួយឯកតា)។ បន្ទុកចំណាយនិងផលចំណេញទៅអនាគត នឹងត្រូវបានកែតម្រូវដោយអត្រាអប្បហារដែលឆ្លុះបញ្ចាំងពីការពិតថា ជាទូទៅ ប្រជាជនឲ្យតម្លៃខ្ពស់ទៅលើចំណាយនៃការប្រើប្រាស់ពេលបច្ចុប្បន្នជាងទៅថ្ងៃក្រោយ។ ការសរុបអំពីការកែតម្រូវបន្ទុកចំណាយនិងផលចំណេញសម្រាប់ជម្រើសនីមួយៗ នឹងផ្តល់នូវរង្វាស់ដែលអាចយកមកប្រើប្រាស់ដើម្បីផ្តល់ព័ត៌មានដល់ការធ្វើសេចក្តីសម្រេច។

នៅពេលដែលផលចំណេញមិនអាចគិតជាតម្លៃបាន ការវិភាគប្រសិទ្ធភាពនៃតម្លៃ ការវិភាគស្ថានភាពរួមដើម និង/ឬការវិភាគតាមបែបគុណភាព អាចយកមកប្រើប្រាស់បាន។

## ការវិភាគប្រសិទ្ធភាពនៃតម្លៃ

ការវិភាគប្រសិទ្ធភាពនៃតម្លៃ ត្រូវបានប្រើប្រាស់ដើម្បីប្រៀបធៀបជម្រើសពីរឬច្រើន នៅពេលដែលផលចំណេញមិនអាចត្រូវបានគណនាជាតម្លៃដោយងាយស្រួល ប៉ុន្តែអាចត្រូវបានកំណត់ជាបរិមាណវិញ។

ជម្រើសប្រសិទ្ធភាពនៃតម្លៃ គឺជាអនុបាតរវាងបន្ទុកចំណាយនិងបរិមាណនៃផលចំណេញ។ ផលធៀបនេះផ្តល់ព័ត៌មានជូនថ្នាក់ដឹកនាំថាតើបន្ទុកចំណាយប៉ុន្មានដើម្បីសម្រេចបានមួយឯកតានៃផល

ចំណេញ។ ដូច្នេះ ថ្នាក់ដឹកនាំអាចជ្រើសរើសថាគោលបំណងចំណាយអនុបាតនេះ (ផលធៀប) នឹងសម្រេចលទ្ធផលនោះបាន។

ជម្រើសប្រសិទ្ធភាពនៃតម្លៃមានអនុបាតទាប នឹងត្រូវបានជ្រើសរើសយក ប៉ុន្តែទោះបីជាជម្រើសដែលមានអនុបាតខ្ពស់ ក៏អាចអនុវត្តបានបើថ្នាក់ដឹកនាំចង់ចំណាយច្រើនដើម្បីសម្រេចលទ្ធផលក៏ដោយ។

## ការវិភាគស្ថានភាពរួចដើម

ការវិភាគស្ថានភាពរួចដើម (BEA - Break Even Analysis) ត្រូវបានប្រើប្រាស់ដើម្បីវិនិច្ឆ័យថា តើជម្រើសដែលសមស្របជាងគេនោះមានប្រយោជន៍ច្រើនជាងបន្ទុកចំណាយនៃជម្រើសនោះ នៅពេលដែលផលចំណេញមិនអាចវាយតម្លៃបាន ឬប្រសិទ្ធភាពនៃបញ្ញត្តិកម្មមានភាពមិនច្បាស់លាស់។

BEA គឺជាការប្រៀបធៀបបរិមាណនៃផលចំណេញនិងបន្ទុកចំណាយ ដើម្បីបង្ហាញថាតើតម្លៃឬចំនួននៃផលចំណេញគួរត្រូវបានគិតគូរដូចម្តេចបើយើងប្រៀបធៀបជាមួយបន្ទុកចំណាយ។ ឧទាហរណ៍ - សំណើបញ្ញត្តិកម្មមួយនឹងត្រូវផ្តល់ផលចំណេញ ១០០០០ដុល្លារចំពោះថ្លៃដើម ប្រសិនមួយឯកតានៃផលចំណេញមានតម្លៃ ១០០០ដុល្លារ ដូច្នេះវាត្រូវផ្តល់ផលចំណេញច្រើនជាង ១០ ឯកតា។

តម្លៃឬចំនួននេះត្រូវតែប្រៀបធៀបនឹងទំហំនៃបញ្ហានិងតម្លៃនៃផលចំណេញដទៃទៀត ដើម្បីធ្វើតេស្តសាកល្បងថា តើវាពិតដូចការរំពឹងទុកចំពោះថ្លៃដើមឬទេ។ ឧទាហរណ៍ - បញ្ហាកើតឡើងតែ៥ដង

ក្នុងមួយឆ្នាំ។ ដូច្នេះ ជម្រើសដែលត្រូវការ១០ដងក្នុងមួយឆ្នាំសម្រាប់ថ្លៃដើម នឹងប្រហែលជាមិនយកមកអនុវត្តទេ។

# ការវិភាគតាមក្រុមក្នុងសង្គម និងតាមគុណភាព

## ការវិភាគតាមគុណភាព

ផលប៉ះពាល់ណាដែលគេមិនអាចគណនាជាតម្លៃបាន គឺប្រសើរបំផុតក្នុងការផ្តល់ឲ្យអ្នកធ្វើសេចក្តីសម្រេចនូវការពិភាក្សាបែបគុណភាពទៅលើប៉ះពាល់នោះ និងទុកឲ្យអ្នកធ្វើសេចក្តីសម្រេចធ្វើការវិនិច្ឆ័យថា តើសំណើបញ្ញត្តិកម្មផ្តល់ផលចំណេញដែលអាចទទួលយកបានដែរឬមិនបាន។

វិធីសាស្ត្រវិភាគតាមបែបពហុលក្ខណវិនិច្ឆ័យ (MCA - Multi-Criteria Analysis) គឺជាបច្ចេកទេសវិភាគដែលគេនិយមប្រើសម្រាប់ធ្វើការវិភាគតាមគុណភាព ហើយធានាថាជម្រើសទាំងអស់ត្រូវបានវាយតម្លៃដោយត្រឹមត្រូវនិងដោយតម្លាភាព។ វាអាចប្រើប្រាស់បានដើម្បីប្រៀបធៀបជម្រើសនីមួយៗ ប៉ុន្តែដោយសារតែលក្ខណៈសត្យានុម័តនៃការដាក់ពិន្ទុ MCA វាមិនអាចប្រើប្រាស់បានដើម្បីកំណត់ថាតើជម្រើសណាមួយនឹងផ្តល់ផលចំណេញដុលនោះទេ។

- ដោយហេតុផលនេះ វិធីសាស្ត្រMCAត្រូវប្រើប្រាស់រួមគ្នាជាមួយការវិភាគប្រសិទ្ធភាពនៃតម្លៃ ឬការវិភាគស្ថានភាពរួចដើមដើម្បីជ្រើសរើសនូវជម្រើសដែលពេញចិត្តជាង។

វិធីសាស្ត្រMCAទាក់ទងនឹងការជ្រើសរើសលក្ខណវិនិច្ឆ័យច្រើនដើម្បីវាយតម្លៃទៅលើជម្រើសនានា។ ជម្រើសទាំងអស់នោះត្រូវបានដាក់ពិន្ទុសម្រាប់លក្ខណវិនិច្ឆ័យនីមួយៗ ហើយពិន្ទុសរុបត្រូវបានប្រើប្រាស់ដើម្បីប្រៀបធៀបជម្រើសទាំងនោះ។

តារាងខាងក្រោមបង្ហាញអំពីឧទាហរណ៍នៃការដាក់ពិន្ទុតាមវិធីសាស្រ្តMCA។ វិធីសាស្រ្តMCAមិនគ្រាន់តែជាតារាងពិន្ទុប៉ុណ្ណោះទេ តែវិធីសាស្រ្តMCAអាចជួយថ្នាក់ដឹកនាំបានលុះណាតែលក្ខណវិនិច្ឆ័យទាំងឡាយត្រូវបានជ្រើសរើសដោយប្រុងប្រយ័ត្ន និងការដាក់ពិន្ទុផ្អែកលើភស្តុតាងបានច្បាស់លាស់។ ការជ្រើសរើសលក្ខណវិនិច្ឆ័យ និងការដាក់ពិន្ទុគួរតែអនុវត្តតាមដំណាក់កាលកំណត់បញ្ហា ការកំណត់បរិមាណ និងការកំណត់តម្លៃដូចបានកំណត់ខាងលើ ហើយការជ្រើសរើសគួរត្រូវបានពន្យល់ដោយប្រុងប្រយ័ត្ន។ ឧទាហរណ៍ - ពិន្ទុប្រៀបធៀបនៃជម្រើសផ្សេងៗគ្នា គួរតែសមាមាត្រទៅនឹងការកំណត់បរិមាណ បើមិនដូច្នោះទេ ការដាក់ពិន្ទុនេះនឹងមិនត្រឹមត្រូវទេ។

| | ជម្រើសទី១ | ជម្រើសទី២ | ជម្រើសទី៣ |
|---|---|---|---|
| លក្ខណវិនិច្ឆ័យ ១ | 3 | 5 | 2 |
| លក្ខណវិនិច្ឆ័យ ២ | 2 | 2 | 2 |
| លក្ខណវិនិច្ឆ័យ ៣ | -1 | -2 | -3 |
| លក្ខណវិនិច្ឆ័យ ៤ | -2 | -2 | -2 |
| សរុប | 2 | 3 | -1 |

## ការវិភាគតាមក្រុមក្នុងសង្គម

ទោះបីជាបញ្ញត្តិកម្មអាចផ្តល់ផលចំណេញដុលដល់សហគមន៍ទាំងមូលក៏ដោយ ជួនកាលវាក៏ប៉ះពាល់ដល់ក្រុមមួយចំនួនខុសៗគ្នាដែរ។ ជាពិសេស នៅពេលដែលបញ្ញត្តិកម្មត្រូវបានព្រាងឡើងដោយមិនបានគិតគូរអំពីបញ្ហាយេនឌ័រ វាអាចប៉ះពាល់ដល់យេនឌ័រមួយ ច្រើនជាងយេនឌ័រមួយទៀត។ ឧទាហរណ៍៖

- ការបង្កើនប្រាក់ឈ្នួលអប្បបរមា អាចប៉ះពាល់ទៅដល់ស្រ្តីច្រើន ប្រសិនបើភាគច្រើននៃបុគ្គលិកដែលមានប្រាក់ឈ្នួលទាបជាស្រ្តី។
- បញ្ញត្តិកម្មដែលប៉ះពាល់ដល់មីក្រូឥណទាន អាចប៉ះពាល់ដល់ស្រ្តីច្រើន ប្រសិនបើភាគច្រើននៃអ្នកទទួលឥណទានជាស្រ្តី។

បញ្ញត្តិកម្មអាចប៉ះពាល់ខុសៗគ្នាដល់តំបន់សាសនា ឬក្រុមវប្បធម៌ផ្សេងៗគ្នា។ ដោយសារតែផលប៉ះពាល់ខុសៗគ្នានេះ ការវាយតម្លៃសំណើបញ្ញត្តិកម្មដែលប៉ះពាល់មិនល្អដល់ក្រុមមួយ គឺជាផ្នែកមួយដ៏សំខាន់នៃការវិភាគផលប៉ះពាល់ទាំងក្នុងPAS ទាំងក្នុងRIS។ តាមពិត ការវិភាគផលប៉ះពាល់ទៅលើយេនឌ័រ គឺជាការតម្រូវតាមច្បាប់ ហើយរបាយការណ៍ផលប៉ះពាល់យេនឌ័រ(GIS) គួរតែរៀបចំ និងបញ្ចូលទៅក្នុងRIS ប្រសិនបើមានផលប៉ះពាល់សំខាន់ទៅលើយេនឌ័រណាមួយ។

ការវិភាគផលប៉ះពាល់ទៅលើក្រុមដោយឡែកណាមួយ អាចធ្វើឡើងជាទម្រង់នៃការវិភាគផលប៉ះពាល់ ដែលបានបង្ហាញពីមុនរួចមកហើយនៅក្នុងការណែនាំនេះ។ ពោលគឺ ការវិភាគគួរតែ ៖

- កំណត់ថា តើសំណើបញ្ញត្តិកម្មនោះប៉ះពាល់យ៉ាងដូចម្តេចដល់ក្រុមពាក់ព័ន្ធ និងតើវាខុសគ្នាដូចម្តេចទៅនឹងផលប៉ះពាល់ទៅលើប្រជាជនទូទៅ
- កំណត់ចំនួនមនុស្សក្នុងក្រុមនោះ និងទំហំនៃផលប៉ះពាល់ខុសៗគ្នាទៅលើក្រុមនោះ
- វាយតម្លៃផលប៉ះពាល់អវិជ្ជមាន (ឬវិជ្ជមាន) ទៅលើក្រុមនោះ។

ក្រុមដែលរងផលប៉ះពាល់ គួរតែពិគ្រោះយោបល់ដាច់ដោយឡែកពីគ្នាដែរ ដើម្បីកត់ត្រាទុកនូវគំនិតរបស់ពួកគេទៅលើសំណើបញ្ញត្តិកម្ម និងដើម្បីស្វែងរកនូវព័ត៌មានត្រឡប់ថាតើផលប៉ះពាល់ខុសៗគ្នានោះអាចត្រូវបានកាត់បន្ថយឬដោះស្រាយដោយរបៀបណា។

# ប្រសិទ្ធភាពនៃការពិគ្រោះយោបល់

## ធាតុទី ៥- ការពិគ្រោះយោបល់

ប្រសិនបើមិនមានការពិគ្រោះយោបល់ទេ ការយល់ដឹងរបស់យើងអំពីបញ្ហា ជម្រើស និងផលប៉ះពាល់នានា នឹងមានភាពខ្វះចន្លោះ។ ការពិគ្រោះយោបល់នឹងជួយដូចខាងក្រោម៖

- ធ្វើឲ្យប្រសើរឡើងនូវការយល់ដឹងអំពីបញ្ហា និងធ្វើឲ្យកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាលដោះស្រាយបញ្ហាតាមតម្រូវការបានដោយគិតបញ្ចូលទាំងការរិះរកនូវជម្រើសដទៃផ្សេងៗ។
- ជួយកំណត់អត្តសញ្ញាណនិងបរិមាណនៃផលប៉ះពាល់នៃកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាល ដោយបង្កភាពងាយស្រួលក្នុងការប្រមូលទិន្នន័យនិងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងផលប៉ះពាល់នៃសំណើបញ្ញត្តិកម្ម ដែលនាំឲ្យជ្រើសរើសបាននូវជម្រើសដែលមានប្រសិទ្ធភាពបំផុត។
- បញ្ចៀសនូវហានិភ័យទាំងឡាយពាក់ព័ន្ធនឹងការអនុវត្តកិច្ចអន្តរាគមន៍របស់រដ្ឋាភិបាល ដែលអាចនឹងធ្វើឲ្យកិច្ចអន្តរាគមន៍ទាំងនោះមានប្រសិទ្ធភាពតិច។
- លើកកម្ពស់តម្លាភាពនិងទំនុកចិត្ត តាមរយៈការបើកចំហនូវស្មារតីនៃការសម្រេច ការសន្ទត និងការវិភាគដើម្បីធ្វើការសម្រេចផ្សេងៗ។

ការពិគ្រោះយោបល់មិនទាមទារឲ្យមានសំណួរចំនួនច្រើនលើសលប់ដែលតម្រូវឲ្យអ្នកពាក់ព័ន្ធបំពេញនោះទេ។ វាមានប្រសិទ្ធភាពច្រើនជាង ដោយគ្រាន់តែសួរសំណួរសំខាន់ៗមួយចំនួនតិចតួចល្មមប៉ុណ្ណោះ ទៅកាន់បុគ្គលដែលជាគោលបំណងពិតប្រាកដ តាមរយៈវេទិកាពិគ្រោះយោបល់។

## បញ្ជីត្រួតពិនិត្យ- ធ្វើដូចម្តេចដើម្បីឲ្យការពិគ្រោះយោបល់មានប្រសិទ្ធភាព?

ត្រូវធានាថា ការពិគ្រោះយោបល់ត្រូវបានធ្វើឡើងជាមួយតំណាងភាគីទាំងអស់ដែលរងផលប៉ះពាល់ពីបញ្ហានិងពីសំណើបញ្ញត្តិកម្មដែលរាប់បញ្ចូលទាំងធុរកិច្ច រាជរដ្ឋាភិបាល សាធារណជន និងអង្គការតំណាងនានា។

ការពិគ្រោះយោបល់ត្រូវធ្វើឡើងច្រើនដង នៅក្នុងដំណើរការនៃការតាក់តែងបញ្ញត្តិកម្ម។ ការពិគ្រោះយោបល់អាចជួយសម្រួលដល់ការកំណត់រកជម្រើស និងការកំណត់គោលបំណង ក៏ដូចជាធ្វើឲ្យប្រសើរឡើងនូវការវិភាគផលប៉ះពាល់ និងកំណត់បញ្ហានៃការអនុវត្ត។

ត្រូវយកចិត្តទុកដាក់ថាអ្នកពាក់ព័ន្ធទាំងឡាយសុទ្ធតែគិតលើផលប្រយោជន៍ក្នុងអំឡុងពេលពិគ្រោះយោបល់។ អាស្រ័យហេតុនេះ យើងត្រូវបើកចិត្តឲ្យទូលាយ និងត្រូវធ្វើការពិនិត្យពិច័យឲ្យបានល្អិតល្អន់ចំពោះរាល់ការលើកឡើងនានារបស់ពួកគេ។

## ពិគ្រោះយោបល់ជាមួយអ្នកណាខ្លះ?

អ្នកពាក់ព័ន្ធដែលយើងគួរពិគ្រោះយោបល់ជាមួយអាចមានច្រើនក្រុម ឬអាចជាក្រុមជាក់លាក់ណាមួយដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងPAS/RISនីមួយៗ។ ជាគោលការណ៍ណែនាំ ការពិគ្រោះយោបល់អាចធ្វើបានជាមួយអ្នកពាក់ព័ន្ធដូចខាងក្រោម៖

- ធុរកិច្ចដែលរងផលប៉ះពាល់ពីបញ្ញត្តិកម្ម - ជាអ្នកដែលគួរត្រូវបានពិគ្រោះយោបល់ជាមួយអំពីបន្ទុកចំណាយនិងការអនុវត្តជម្រើសនីមួយៗ។
- អ្នកប្រើប្រាស់និងបុគ្គលដទៃដែលរងឥទ្ធិពលពីបញ្ហាឬសំណើបញ្ញត្តិកម្ម - ជាអ្នកដែលអាចផ្តល់ភស្តុតាងនៃបញ្ហាឬប្រសិទ្ធភាពរបស់ជម្រើសនីមួយៗ។
- អង្គការតំណាងផ្សេងៗ (សភាពាណិជ្ជកម្ម ក្រុមឧស្សាហកម្ម សមាគមអ្នកប្រើប្រាស់ អង្គការមិនមែនរដ្ឋាភិបាល) ដែលអាចមានលទ្ធភាពផ្តល់ឲ្យអ្នកនូវទស្សនវិស័យទូលំទូលាយ។
- ទីភ្នាក់ងាររដ្ឋាភិបាលទាំងឡាយ ដែលនឹងជួយជ្រោមជ្រែងក្នុងការអនុវត្តសំណើបញ្ញត្តិកម្ម (វិទ្យាស្ថានស្តង់ដាកម្ពុជា នគរបាលភ្នាក់ងារគយ ឬក្រសួងដទៃទៀត)។
- ទីភ្នាក់ងាររដ្ឋាភិបាលទាំងឡាយ ដែលគ្រប់គ្រងឧស្សាហកម្មដូចគ្នាដើម្បីធានាថា សំណើបញ្ញតិកម្មរបស់អ្នកមិនជាន់សមត្ថកិច្ច

ជាមួយបញ្ញត្តិកម្មដែលមានស្រាប់ ក៏ដូចជាបទប្បញ្ញត្តិអន្តរជាតិផ្សេងៗ។

- ក្រុមការងារយេនឌ័រនិងក្រុមការងារបញ្ជ្រាបយេនឌ័រនៅក្នុងស្ថាប័នរបស់អ្នក និងនៅក្នុងក្រសួងកិច្ចការនារី ដើម្បីធានាថារាល់ផលប៉ះពាល់ទៅលើយេនឌ័រត្រូវបានទទួលស្គាល់។
- បណ្ឌិតសភាឬអ្នកឯកទេសដទៃទៀត ដែលយល់ដឹងច្បាស់អំពីវិស័យដែលនឹងត្រូវបានគ្រប់គ្រងដោយសំណើបញ្ញត្តិកម្ម ជាអ្នកដែលអាចបង្ហាញទស្សនៈមិនលម្អៀង ឬអាចយល់ដឹងអំពីបញ្ញតិកម្មស្រដៀងគ្នានៅក្នុងប្រទេសផ្សេងទៀត។

យើងត្រូវយកចិត្តទុកដាក់ថា អ្នកពាក់ព័ន្ធទាំងឡាយសុទ្ធតែគិតពីផលប្រយោជន៍ដល់ការពិគ្រោះយោបល់ អាស្រ័យហេតុនេះត្រូវបើកចិត្តឲ្យទូលាយ និងត្រូវធ្វើការពិនិត្យពិច័យឲ្យបានល្អិតល្អន់ចំពោះរាល់ការលើកឡើងនានារបស់ពួកគេ។ អ្នកមិនចាំបាច់យល់ស្របទៅនឹងទស្សនៈរបស់ពួកគេទេ ក៏ប៉ុន្តែ អ្នកត្រូវតែទទួលយកមកពិចារណា និងធ្វើការឆ្លើយតបទៅពួកគេវិញ។

ព័ត៌មានផ្តល់ដោយអ្នកពាក់ព័ន្ធមានប្រសិទ្ធភាពបំផុតនៅពេលដែលវាត្រូវបានផ្សព្វផ្សាយជាមួយPAS/RIS ទោះបីជាក្នុងទម្រង់សង្ខេបក៏ដោយ។ យ៉ាងណាមិញ យើងត្រូវគោរពសំណើសុំរក្សាការសម្ងាត់របស់អ្នកពាក់ព័ន្ធ។

## ទម្រង់នៃការពិគ្រោះយោបល់

ការពិគ្រោះយោបល់អាចធ្វើឡើងក្នុងទម្រង់ជាច្រើនដូចជា កិច្ចប្រជុំសិក្ខាសាលា វគ្គសិក្សា យោបល់ជាលាយលក្ខណ៍អក្សរ (អាចធ្វើឡើងតាមរយៈការផ្សាយជាសាធារណៈលើទំព័រកាសែត ឬទំនាក់ទំនងដោយផ្ទាល់ទៅកាន់អ្នកពាក់ព័ន្ធនីមួយៗ) ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមនានា។

ទម្រង់នៃការពិគ្រោះយោបល់ដែលអ្នកជ្រើសរើសគួរ ៖

- អនុញ្ញាតឲ្យមានការចូលរួមយ៉ាងទូលំទូលាយពីក្រុមអ្នកពាក់ព័ន្ធ ដើម្បីធានាថា រាល់អ្នកពាក់ព័ន្ធដែលទទួលរងផលប៉ះពាល់ពីសំណើបញ្ញតិកម្ម ត្រូវបានពិគ្រោះយោបល់។
- ពន្យារយៈពេលនៃដំណើរការតាក់តែងបញ្ញត្តិកម្ម ដើម្បីអនុញ្ញាតិឲ្យអ្នកពាក់ព័ន្ធអាចផ្តល់មតិយោបល់អំពីជម្រើសទាំងឡាយ និងគោលបំណង ក៏ដូចជាសំណើបញ្ញត្តិកម្មចុងក្រោយ។
- ផ្តល់ពេលវេលាគ្រប់គ្រាន់និងរក្សាការសម្ងាត់ ដើម្បីអនុញ្ញាតឲ្យអ្នកពាក់ព័ន្ធអាចផ្តល់យោបល់ជាលាយលក្ខណ៍អក្សរដោយមិនមានក្តីបារម្ភថា ព័ត៌មាននឹងត្រូវប្រើប្រាស់ខុសទិសដៅ ឧទាហរណ៍ - អ្នកនឹងមានសំណូមពរពិគ្រោះយោបល់ជាមួយក្រុមខ្លះនៅក្នុងវេទិកាផ្សេងគ្នា។

## PAS/RIS ជាឯកសារពិគ្រោះយោបល់

PAS/RISជាឯកសារពិគ្រោះយោបល់ ក៏ដូចជាសេចក្តីថ្លែងការណ៍អំពីសំណើរបស់រដ្ឋាភិបាលដែរ។ នេះជាការត្រូវចងចាំរាល់ពេលដែលអ្នកធ្វើសេចក្តីព្រាងឯកសារទាំងពីរខាងលើ។

- ក្នុងសេចក្តីព្រាងត្រូវប្រើប្រាស់ភាសាដែលអ្នកពាក់ព័ន្ធទាំងអស់អាចយល់បាន ដោយកុំដកស្រង់សេចក្តីព្រាងបញ្ញត្តិកម្មមកនិយាយតែម្តង តែត្រូវអធិប្បាយថា តើសេចក្តីព្រាងនេះនឹងដោះស្រាយបញ្ហាយ៉ាងដូចម្តេច។
- ព័ត៌មានមួយចំនួនអំពីបញ្ហានិងផលប៉ះពាល់ អាចខ្វះខាតក្នុងអំឡុងពេលព្រាងPAS/RIS បើដូច្នេះ អ្នកត្រូវរៀបចំសំនួរដើម្បីបានព័ត៌មានត្រឡប់ពីអ្នកពាក់ព័ន្ធ។
- រាប់បញ្ចូលផងដែរនូវលទ្ធផលនៃការពិគ្រោះយោបល់ដែលបានធ្វើ។

ព័ត៌មានទទួលបានពីអ្នកពាក់ព័ន្ធត្រូវប្រើប្រាស់ ដើម្បីបង្កើនគុណភាពនៃការវិភាគក្នុងអំឡុងពេលព្រាង រាប់បញ្ចូលទាំងក្រោយពេលRISត្រូវបានបោះពុម្ពផ្សាយផង។

# ការជ្រើសរើសជម្រើសដែលសមស្របជាងគេ

## ធាតុទី៦- ការសន្និដ្ឋាន

នៅពេលដែលការវិភាគផលប៉ះពាល់បានចប់សព្វគ្រប់ ស្មារតីនៃជម្រើសផ្សេងៗដែលបានជ្រើសរើសមកពិចារណា គួរត្រូវធ្វើការប្រៀបធៀប។ ការវាយតម្លៃត្រូវយកមកគិតគូរនូវលទ្ធផលនៃការវិភាគផលប៉ះពាល់នៃផលប៉ះពាល់លើក្រុមផ្សេងៗក្នុងសង្គម និងគុណភាពនៃភស្តុតាងដែលមាន។

ជម្រើសជាអនុសាសន៍ត្រូវកំណត់ដោយការពន្យល់ថា តើហេតុអ្វីបានជាជម្រើសនោះសមស្របជាងគេ ហើយក៏ត្រូវផ្តល់មូលហេតុលម្អិតដែលបដិសេធជម្រើសផ្សេងៗទៀតដែរ។

ទម្រង់នៃសេចក្តីសន្និដ្ឋាននឹងផ្អែកលើវិធីសាស្ត្រ ដែលប្រើប្រាស់ក្នុងការវិភាគផលប៉ះពាល់៖

- ក្នុងករណីដែលមានការវិភាគបន្ទុកចំណាយនិងផលចំណេញនៃការសន្និដ្ឋាននឹងធ្វើការប្រៀបធៀបផលចំណេញដុលរវាងជម្រើសនីមួយៗ (ផលចំណេញដកបន្ទុកចំណាយ) ដោយយកលទ្ធផលនេះជាមូលដ្ឋានក្នុងការជ្រើសរើសជម្រើសដែលសមស្របជាងគេ
- ចំពោះPAS/RISដែលបង្ហាញបច្ច័យហានិភ័យខ្ពស់ជាបញ្ហាជម្រើសសមស្របគួរជាជម្រើសដែលមានប្រសិទ្ធិភាពជាងគេក្នុងការកាត់បន្ថយហានិភ័យ ដោយមិនចាំបាច់គិតអំពីបន្ទុកចំណាយ ជាពិសេសក្នុងករណីដែលផលចំណេញមិនអាចកំណត់តម្លៃជាប្រាក់បាន
- ការវិភាគស្ថានភាពរួចដើមឬការវិភាគប្រសិទ្ធភាពនៃតម្លៃ អាចយកមកប្រើប្រាស់ ដើម្បីកំណត់ថាតើត្រូវបន្តជាមួយជម្រើស

ណាមួយ ប៉ុន្តែការវិភាគទាំងនេះគ្មានប្រយោជន៍សម្រាប់ការប្រៀបធៀបជម្រើស ដែលទាមទារការវិភាគតាមគុណភាពនោះទេ

- ពេលដែលការសម្រេចត្រូវបានធ្វើឡើង ដោយឈរលើមូលដ្ឋាននៃការវិភាគតាមគុណភាព បន្ទាប់មកលក្ខណវិនិច្ឆ័យនិងការវាយតម្លៃទៅលើជម្រើសនីមួយៗធៀបនឹងលក្ខណវិនិច្ឆ័យ ត្រូវបញ្ជាក់ឲ្យបានច្បាស់ ឬក៏ប្រើប្រាស់ការវិភាគតាមបែបពហុលក្ខណវិនិច្ឆ័យវិញ។

ការសន្មតសំខាន់ៗ ត្រូវបានយកចិត្តទុកដាក់ និងធ្វើតេស្តសាកល្បងដោយប្រើប្រាស់តម្លៃជំនួស ដើម្បីធានាថាសេចក្តីផ្តានដូចគ្នានៅរក្សាបាន ទោះបីជាស្ថិតក្នុងខណៈមិនប្រសើរក៏ដោយ។ យោបល់អ្នកពាក់ព័ន្ធមានប្រយោជន៍ដែលយើងមិនអាចចោលបាន ក្នុងករណីដែលយើងមិនច្បាស់លាស់ក្នុងធាតុណាមួយ។

## ពិចារណាលើភាពមិនប្រាកដប្រជា

RIAទាំងអស់មានការពាក់ព័ន្ធនឹងការសន្មតទៅលើអ្វីដែលនឹងកើតឡើងនាពេលអនាគត ដូចជា៖

- ទំហំនៃបញ្ហាដែលត្រូវដោះស្រាយ និងបញ្ញត្តិកម្មដែលមានប្រសិទ្ធភាព នឹងដោះស្រាយបញ្ហាបានយ៉ាងណា។
- ការផ្លាស់ប្តូរឥរិយាបថរបស់ធុរកិច្ចនិងបុគ្គលម្នាក់ៗ ដែលបណ្តាលមកពីបញ្ញត្តិកម្មថ្មីនេះ។

ការប្រែប្រួលតិចតួចនៃការសន្មតទាំងនេះ អាចធ្វើឲ្យជម្រើសផ្សេងទៅជាបានជ្រើសរើស។ សារៈសំខាន់នៃការសន្មតជាក់លាក់ទាំងឡាយ និងការប្រែប្រួលនៃសេចក្តីសន្និដ្ឋាន ដែលកើតចេញពីការកែតម្រូវការសន្មតទាំងនោះ ត្រូវកត់សម្គាល់ក្នុងសេចក្តីសន្និដ្ឋាន។

វាមានសារៈសំខាន់នៅពេលដែលអ្នកអានPASឬRIS មានព័ត៌មានដែលអាចប្រើប្រាស់ ដើម្បីប៉ាន់ស្មានបន្ទុកចំណាយនិងផលចំណេញ។ ពេលមានការបង្ហាញសេចក្តីសង្ខេបនៃការសន្មតសំខាន់ៗ អញ្ជើញពួកគេឲ្យផ្តល់ព័ត៌មានត្រឡប់។

## ប្រើប្រាស់ភាសាសមស្រប

នៅក្នុងព្រះរាជាណាចក្រកម្ពុជា PAS/RISភាគច្រើននឹងប្រើប្រាស់វិធីសាស្រ្តបែបគុណភាព ដើម្បីវិភាគផលប៉ះពាល់នៃជម្រើសទាំងឡាយ ដូចជាការវិភាគពហុលក្ខណវិនិច្ឆ័យ ឬការពិភាក្សាយ៉ាងលម្អិតអំពីជម្រើសនីមួយៗ។

ការបង្ហាញយ៉ាងត្រឹមត្រូវនូវលទ្ធផលនៃការវិភាគដោយប្រើប្រាស់វិធីសាស្រ្តបែបគុណភាពមានសារៈសំខាន់ណាស់។ ឧទាហរណ៍ : ការវិភាគតាមគុណភាពមួយ គឺជាសេចក្តីថ្លែងការណ៍អំពីគំនិត និងការចង់បានរបស់អ្នកតាក់តែង។ ជម្រើសដែលត្រូវបានជ្រើសរើស គឺជាជម្រើសដែលឃើញសមស្របជាងក្នុងចំណោមជម្រើសនានាតែប៉ុណ្ណោះ ហើយយើងក៏មិនត្រូវបង្ហាញថាប្រសើរពិតប្រាកដដែរ។

សេចក្តីសន្និដ្ឋានគួរចៀសវាង គឺការប្រើប្រាស់ពាក្យដែលបង្ហាញថា ជម្រើសដែលត្រូវបានជ្រើសរើសមានលក្ខណៈប្រសើរពិតប្រាកដជាងជម្រើសដទៃទៀត ដូចជាថ្លែងថា វាជាជម្រើសដែលមាន "ផលចំណេញខ្ពស់បំផុត" "ល្អបំផុត" ឬ "មានផលចំណេញច្រើនជាងបន្ទុកចំណាយ"។ ការលើកឡើងបែបនេះអាចធ្វើទៅបានលុះត្រាតែមានការវិភាគបន្ទុកចំណាយនិងផលចំណេញយ៉ាងស៊ីជម្រៅ។

បើនិយាយឲ្យខ្លី គឺយើងត្រូវមានភាពស្មោះត្រង់ចំពោះរាល់ការវិភាគដែលបានធ្វើឡើង។

# ការធានាថា
# បញ្ញត្តិកម្មដែលជ្រើសរើសអាចអនុវត្តបាន

## ធាតុទី ៧- ការអនុវត្ត និងការតាមដានត្រួតពិនិត្យ

ចំណុចចុងក្រោយនៃRIA គឺការពិចារណាអំពីសេចក្តីលម្អិតការងាយអនុវត្ត និងបញ្ហាផ្សេងៗដែលត្រូវដោះស្រាយ មុនពេលជម្រើសដែលឃើញសមស្របជាងត្រូវបានអនុម័ត។

លើកផែនការសម្រាប់ការអនុវត្តនិងការតាមដានត្រួតពិនិត្យនៅក្នុងRIA អាចធ្វើឲ្យការតាក់តែងបញ្ញត្តិកម្មកាន់តែប្រសើរឡើង និងបញ្ចៀសរាល់បន្ទុកចំណាយមិនចាំបាច់ដើម្បីប្រតិបត្តិតាម។ ការនេះអាចបង្កើនប្រសិទ្ធភាពនៃបញ្ញត្តិកម្ម ដោយសារយើងមានផែនការដើម្បីទប់ស្កាត់ឧបសគ្គផ្សេងៗជាមុន។

សម្រាប់ធាតុទី៧នៃPASឬRIS ដំណើរការនៃការអនុវត្តត្រូវអធិប្បាយដោយរាប់បញ្ចូល៖

- កាលបរិច្ឆេទដែលបញ្ញត្តិកម្មនឹងមានសុពលភាព
- សេចក្តីលម្អិតអំពីនាយកដ្ឋាន/ទីភ្នាក់ងារដែលនឹងគ្រប់គ្រង និង/ឬដាក់ឱ្យអនុវត្តសំណើបញ្ញត្តិកម្ម និងតួនាទីរបស់ពួកគេ
- ប្រភពព័ត៌មានអំពីបញ្ញត្តិកម្ម ដែលសាធារណជនអាចពិគ្រោះយោបល់ដើម្បីយល់ដឹងបន្ថែមអំពីរបៀបប្រតិបត្តិតាមបញ្ញាត្តិកម្ម (ឧទាហរណ៍ - ធ្វើដូចម្តេចដើម្បីស្នើសុំអាជ្ញាបណ្ណ)។
- មធ្យោបាយអន្តរកាលនីមួយៗដើម្បីកាត់បន្ថយផលប៉ះពាល់ដំបូងនៃបញ្ញត្តិកម្ម (ឧទាហរណ៍ - ការទាមទារឲ្យអនុវត្ត

កាតព្វកិច្ចយ៉ាងសន្សឹមៗ ការជូនព័ត៌មានទៅកាន់ធុរកិច្ចដែលទទួលរងផលប៉ះពាល់)។

- យន្តការតាមដានការអនុវត្តបញ្ញត្តិកម្ម រាប់បញ្ចូលទាំងការប្រើប្រាស់នូវការវាស់វែងលទ្ធផលនៃការអនុវត្ត និងការកំណត់ពេលវេលាសម្រាប់ការប្រមូលទិន្នន័យនិងធ្វើរបាយការណ៍។

ការអនុវត្តបញ្ញត្តិកម្មទាមទារនូវការកំណត់ផែនការយ៉ាងប្រុងប្រយ័ត្ន និងការងារផ្សេងៗទៀតជាច្រើន ព្រោះថាបញ្ញត្តិកម្មនឹងមិនមានសុពលភាពដោយងាយៗ តាមរយៈការចុះហត្ថលេខាដើម្បីឲ្យក្លាយទៅជាច្បាប់តែប៉ុណ្ណោះទេ។

ប្រសិនបើទីភ្នាក់ងារផ្សេងទៀតរបស់រដ្ឋាភិបាល តម្រូវឲ្យជួយដល់ការអនុវត្តបញ្ញត្តិកម្ម (ឧទាហរណ៍ - នគរបាល) ទីភ្នាក់ងារអនុវត្តត្រូវធានាថាអ្នកទាំងអស់នោះយល់ដឹងពីតួនាទីរបស់ខ្លួន និងមានសមត្ថភាពអនុវត្តរាល់ភារកិច្ចដែលតម្រូវសម្រាប់ពួកគេ។

# ឧបសម្ព័ន្ធ ១
# ទម្រង់នៃការវាយតម្លៃបឋមលើផលប៉ះពាល់

# ការវាយតម្លៃបឋមលើផលប៉ះពាល់

[បញ្ចូលឈ្មោះសំណើបញ្ញត្តិកម្ម]

[បញ្ចូលឈ្មោះ ក្រសួង/ស្ថាប័ន]

លេខយោង: [បញ្ចូលលេខយោងដែលមានតែមួយគត់-មូលដ្ឋានទិន្នន័យ]

កាលបរិច្ឆេទចាប់ផ្តើម : [ថ្ងៃ - ខែ - ឆ្នាំ]

កាលបរិច្ឆេទបញ្ចប់ : [ថ្ងៃ - ខែ - ឆ្នាំ]

## អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម

(រៀបរាប់ពីធាតុសំខាន់ៗ ដូចជាកាតព្វកិច្ច វិសាលភាព និងគោលបំណង)

| |
|---|
| |

## ប្រភេទបញ្ញត្តិកម្ម

*សូមគូសសញ្ញាក្នុងប្រអប់ឲ្យត្រូវនឹងប្រភេទបញ្ញត្តិកម្មណាមួយ ហើយសូមអធិប្បាយ ប្រសិនបើសំណើនោះជាប្រភេទផ្សេងទៀត។*

| ច្បាប់ | ព្រះរាជក្រឹត្យ | អនុក្រឹត្យ | ប្រកាស | សេចក្តីសម្រេច | សារាចរ | ផ្សេងទៀត |
|---|---|---|---|---|---|---|
| ☐ | ☐ | ☐ | ☐ | ☐ | ☐ | ☐ |

ផលប៉ះពាល់ចម្បងនៃសំណើបញ្ញត្តិកម្មលើវិស័យ ៖

**☐ សេដ្ឋកិច្ច ☐ សង្គមកិច្ច ☐ បរិស្ថាន ☐ ផ្សេងៗ**

## ១. ការកំណត់បញ្ហា

*បញ្ហាមានដូចជា សុខភាពនិងសុវត្ថិភាពសាធារណៈ ការការពារនិងអភិរក្សបរិស្ថាន សង្គមកិច្ច សមធម៌យេនឌ័រនិងការអភិរក្សវប្បធម៌ ការប្រកួតប្រជែង ការប្រមូលព័ត៌មាន ការអនុវត្តតាមកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗលៗ*

១.ក. បញ្ហាចម្បងដែលបញ្ញត្តិកម្មមានបំណងដោះស្រាយ ដោយផ្តល់អំណះអំណាង (ភស្តុតាង/ភាពជាក់ស្តែង ប្រសិនបើចាំបាច់)

| |
|---|
| |

១.ខ. បញ្ហាពាក់ព័ន្ធផ្សេងទៀតដែលបញ្ញត្តិកម្មអាចជួយដោះស្រាយផងដែរ ដោយផ្តល់អំណះអំណាង (ភស្តុតាង/ភាពជាក់ស្តែង ប្រសិនបើចាំបាច់)

| |
|---|
| |

១.គ. សូមរាយបញ្ជីលិខិតបទដ្ឋានគតិយុត្តមានស្រាប់ ដែលពាក់ព័ន្ធឬប្រហាក់ប្រហែល។

ចូរបញ្ជាក់ថា តើហេតុអ្វីបានជាលិខិតបទដ្ឋានគតិយុត្តទាំងនេះមិនទាន់គ្រប់គ្រាន់?

| |
|---|
| ១. |
| ២. |
| . . . . |

*(ពន្យល់ថាតើហេតុអ្វីបានជាបញ្ញត្តិកម្មទាំងនេះមិនដំណើរការ? តើលិខិតបទដ្ឋានគតិយុត្តទាំងនេះមិនអាចអនុវត្តបានពេញលេញឬ? តើយើងអាចកែលម្អលិខិតបទដ្ឋានគតិយុត្តណាមួយដើម្បីសម្រេចបាននូវគោលបំណងដែលបានកំណត់ដែរឬទេ? តើយើងអាចពង្រឹងការអនុវត្តច្បាប់ដើម្បីដោះស្រាយបញ្ហាបានដែរឬទេ?)*

**១.ឃ. តើសំណើបញ្ញត្តិកម្មមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងដែរឬទេ?** (ប្រសិនបើមាន សូមពន្យល់)

## ២. គោលបំណង - តើយើងចង់សម្រេចបានអ្វី?

*ចូរបញ្ជាក់អំពីគោលបំណង(លទ្ធផល)ចុងក្រោយ មិនមែនគ្រាន់តែជាលទ្ធផលភ្លាមៗ ឬជាមធ្យោបាយនោះទេ។ (សូមជៀសវាងការលើកឡើងអំពីមធ្យោបាយដោះស្រាយដើម្បីសម្រេចគោលបំណងនៅធាតុនេះ)។ មិនត្រូវកំណត់គោលបំណងឲ្យចង្អៀតពេកទេព្រោះនាំឲ្យរឹតត្បិតជម្រើស តែក៏មិនត្រូវឲ្យទូលំទូលាយពេកឬមិនច្បាស់លាស់ ដែលនឹងធ្វើឲ្យការវិភាគមានការលំបាក។ សូមផ្សារភ្ជាប់ទៅនឹងគោលបំណងនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលប្រសិនបើពាក់ព័ន្ធ។ ការកៀរគរចំណូល ឬបង្កើតឥទ្ធិពលសម្រាប់ស្ថាប័ន មិនមែនជាគោលបំណងសមស្របរបស់បញ្ញត្តិកម្មទេ។*

## ៣. ជម្រើស

ជម្រើសផ្សេងៗរួមទាំងសំណើបញ្ញត្តិកម្ម (សម្រាប់ការវិភាគលើផលប៉ះពាល់)

*សូមពិចារណារកជម្រើសផ្សេងទៀតជាការសំខាន់ ហើយសូមកត់សម្គាល់ថាបញ្ញត្តិកម្មមិនមែនជាជម្រើសដំបូងបង្អស់នោះទេ។*

| |
|---|
| ១.<br>២.<br>. . . |

## ៤. ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយភាគព្វកិច្ច និងផលចំណេញ

### ៤.១. ការកំណត់ភារកិច្ច និងប្រភេទបន្ទុកចំណាយ

*តារាងខាងក្រោមនេះគ្រាន់តែរំលេចពីប្រភេទបន្ទុកចំណាយតែប៉ុណ្ណោះ ពុំចាំបាច់ការគណនាលម្អិតទេ។*

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| សំណើបញ្ញត្តិកម្ម: ……… | | |
| ជម្រើសទី១: …………… | | |
| ជម្រើសទី២: ………….. | | |

### ៤.២. ការកំណត់ប្រភេទនៃផលចំណេញ

*តារាងខាងក្រោមនេះរំលេចពីប្រភេទផលចំណេញ។*

| ជម្រើស | ប្រភេទនៃផលចំណេញ |
|---|---|
| សំណើបញ្ញត្តិកម្ម: ...... | |
| ជម្រើសទី១: ............ | |
| ជម្រើសទី២: ......... | |

## ៤.៣. វិសាលភាពនៃជម្រើសនីមួយៗ

*ចូររៀបរាប់អំពីវិស័យ ឬប្រភេទធុរកិច្ចដែលរងឥទ្ធិពល ព្រមទាំងធ្វើការព្យាករផលប៉ះពាល់ពីការអនុវត្តតាមជម្រើសដែលបានស្នើឡើង។ (សូមផ្តល់ភស្តុតាងដើម្បីគាំទ្រការប៉ាន់ស្មាននេះ)*

| ជម្រើស | វិស័យ ឬប្រភេទ ធុរកិច្ច | ចំនួន ធុរកិច្ច | ឯកសារ យោង/ ភស្តុតាង |
|---|---|---|---|
| សំណើបញ្ញត្តិកម្ម: ... | | | |
| ជម្រើសទី១: ......... | | | |
| ជម្រើសទី២: ......... | | | |

## ៥. កិច្ចពិគ្រោះយោបល់

កិច្ចពិគ្រោះយោបល់នេះមានគោលបំណងធ្វើឲ្យធាតុខាងលើកាន់តែប្រសើរឡើង។ កិច្ចពិគ្រោះយោបល់ជាមួយសំណាកនៃអ្នកពាក់ព័ន្ធ (Sample)។ សូមធ្វើជារបៀបការប្រជុំប្រមូលគំនិត (brainstorming session) ឬការពិគ្រោះយោបល់ជាក្រុមជំនាញ (focus group interviews)។

កិច្ចពិគ្រោះយោបល់លម្អិតអាចធ្វើឡើងតាមក្រោយ ប្រសិនបើតម្រូវឲ្យមាន RIS ។

## ៦. សន្និដ្ឋាន

សន្និដ្ឋានបឋមដោយផ្អែកលើប្រភេទចំណាយនិងផលចំណេញនៃជម្រើសនីមួយៗថា តើជម្រើសណាមួយត្រូវបានរំពឹងថានឹងផ្តល់ផលចំណេញច្រើនជាងគេ ឬមានបន្ទុកចំណាយច្រើនជាងគេ ឬមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែង។

**តើចាំបាច់ធ្វើ RIS ដែរឬទេ?**

☐**ចាំបាច់** - *សូមបញ្ចប់ការវាយតម្លៃបឋមលើផលប៉ះពាល់(PAS) ហើយចាប់ផ្តើមរៀបចំការវាយតម្លៃពេញលេញលើផលប៉ះពាល់ (RIS) ប្រសិនបើការវាយតម្លៃបឋមលើផលប៉ះពាល់បង្ហាញថា សំណើបញ្ញត្តិកម្មនោះមានផលប៉ះពាល់អវិជ្ជមានគួរឲ្យកត់សម្គាល់ដល់សេដ្ឋកិច្ច-សង្គមកិច្ច ឬដល់ការប្រកួតប្រជែង។*

☐**មិនចាំបាច់** - *សូមផ្តល់អំណះអំណាងនិងបំពេញការវាយតម្លៃបឋមលើផលប៉ះពាល់(PAS) ដែលនៅសេសសល់។*

*(នេះត្រូវផ្អែកទៅលើកម្រិតនៃភាពសំខាន់នៃចំណាយកាតព្វកិច្ចបន្ថែម និងផលចំណេញ ហើយពិចារណាផងថា តើមានផលប៉ះពាល់ដល់ការប្រកួតប្រជែងដែរឬទេ)*

| |
|---|
| ផ្តល់អំណះអំណាងសម្រាប់ការមិនរៀបចំធ្វើRIS |

## ៧. **ការអនុវត្ត និងការតាមដានត្រួតពិនិត្យ**

ប្រសិនបើជម្រើសបញ្ញត្តិកម្មត្រូវបានជ្រើសរើសៈ

**៧.១.** តើវិធានការអ្វីត្រូវបានជ្រើសរើសដើម្បីលើកកម្ពស់តម្លាភាព និងអភិបាលកិច្ចល្អក្នុងអំឡុងពេលនៃការប្រតិបត្តិ?

| |
|---|
| |

**៧.២.** តើគួរធ្វើការពិនិត្យ/តាមដានបញ្ញត្តិកម្មនេះឡើងវិញ ក្រោយពេលបញ្ញត្តិកម្មនេះត្រូវបានប្រតិបត្តិដែរឬទេ? បើដូច្នោះ តើបញ្ញត្តិកម្មនេះគួរត្រូវបានពិនិត្យឡើងវិញ/តាមដានយ៉ាងដូចម្តេច និងនៅពេលណា?

| |
|---|
| |

## អត្ថាធិប្បាយផ្សេងទៀត

| |
|---|
| |

| ដំណើរការ | ឈ្មោះ | មុខងារ | កាលបរិច្ឆេទ | ទំនាក់ទំនង |
|---|---|---|---|---|
| រៀបចំដោយ (ក្រសួងពាក់ព័ន្ធ) | | | | |
| | | | | |
| | | | | |
| | | | | |
| ពិនិត្យ និង ផ្តល់យោបល់ដោយ (ORIA) | | | | |
| | | | | |
| | | | | |
| បញ្ចូលទិន្នន័យដោយ | | | | |
| បញ្ចូលក្នុងគេហទំព័រដោយ | | | | |

# ឧបសម្ព័ន្ធ ២: តារាងត្រួតពិនិត្យ នៃការវាយតម្លៃបឋម

# លំហូរ- ដំណើរការនៃការវាយតម្លៃបឋម



# បញ្ជីត្រួតពិនិត្យ( Checklist )សម្រាប់ការវាយតម្លៃបឋមលើផលប៉ះពាល់

| ធាតុសំខាន់ | អត្ថាធិប្បាយ | ការណែនាំ |
|---|---|---|
| **១. បញ្ហា**<br><br>ហេតុអ្វីបានជាបង្កើតបញ្ញត្តិកម្ម? | – មូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ការវាយតម្លៃ<br><br>– បង្ហាញភស្តុតាង គឺមិនមែនជាការយល់ឃើញឬការអះអាងដោយខ្លួនឯងនោះទេ | – តើមានអ្វីខុសគ្នាប្រសិនបើមិនបង្កើតបញ្ញត្តិកម្ម?<br>– ហេតុអ្វីបានជាទីផ្សារមិនអាចដោះស្រាយបញ្ហាបាន?<br>– ហេតុអ្វីបានជាបញ្ញត្តិកម្មដែលមានស្រាប់ មិនអាចដោះស្រាយបញ្ហាបាន?<br>– តើបញ្ញត្តិកម្មដែលត្រូវបង្កើតនឹងធ្វើឲ្យស្ថានភាពកាន់តែល្អយ៉ាងដូចម្តេច? |
| **២. គោលបំណង**<br><br>តើចង់សម្រេចបានអ្វី? | កំណត់គោលបំណងចុងក្រោយ មិនមែនគោលបំណងនៃការបង្កើតបញ្ញត្តិកម្មនោះទេ? ឧទាហរណ៍៖<br>– កាត់បន្ថយចំនួននៃការបាត់បង់ជីវិតដោយគ្រោះថ្នាក់ចរាចរណ៍ (ជាគោលបំណងចុងក្រោយ)<br>– តម្រូវឲ្យអ្នកបើកបរម៉ូតូពាក់មួកសុវត្ថិភាព កំណត់ល្បឿនបើកបរ ត្រួតពិនិត្យភ្លើងចរាចរណ៍ ...... (ជាគោលបំណងនៃការបង្កើតបញ្ញត្តិកម្ម) | – គិតអំពីអ្វីដែលនឹងត្រូវសម្រេចបាន (លទ្ធផលចុងក្រោយ) ពីការចេញបញ្ញត្តិកម្ម កុំគិតពីវិធីសាស្ត្រ ឬរបៀបណាដែលធ្វើឲ្យ សម្រេចគោលបំណង?<br><br>– (ចៀសវាងការកំណត់គោលបំណងទូលាយពេក ឬចង្អៀតពេក) |

| | | |
|---|---|---|
| **៣. ជម្រើស** | កំណត់ជម្រើសផ្សេងៗ (ដែលអាចដោះស្រាយបញ្ហា និងសម្រេចគោលបំណងចុងក្រោយបាន) | ពិចារណាអំពីជម្រើសនានាឲ្យបានច្រើន (ជ្រើសរើសជម្រើសណាដែលអាចអនុវត្តបាន) |
| **៤. ការវាយតម្លៃលើផលប៉ះពាល់** | – ពិចារណាពីផលប៉ះពាល់នៃជម្រើសនីមួយៗទៅលើអ្នកពាក់ព័ន្ធ<br>– ពិចារណាផលប៉ះពាល់ទៅលើសមភាពយេនឌ័រ<br>– ពិចារណាផលប៉ះពាល់លើការប្រកួតប្រជែង …… | – កំណត់ជាបរិមាណនៃបន្ទុកចំណាយកាតព្វកិច្ចរបស់រដ្ឋាភិបាល ធុរកិច្ច សហគមន៍ និងបុគ្គល។<br>– ប៉ាន់ស្មានបន្ទុកចំណាយ និងផលចំណេញរបស់រដ្ឋាភិបាល ធុរកិច្ច សហគមន៍ និងបុគ្គល។ |
| **៥. ការពិគ្រោះយោបល់** | – ធ្វើឡើងនៅគ្រប់ដំណាក់កាលនៃដំណើរការ នៃការរៀបចំរបាយការណ៍វាយតម្លៃ និងការតាក់តែងបញ្ញត្តិកម្ម ជាពិសេស ដំណាក់កាលទី៣ និងទី៤<br>– ពិចារណាពីសមភាពយេនឌ័រ | – កំណត់អ្នកពាក់ព័ន្ធ<br>– សួរយោបល់ពីអ្នកពាក់ព័ន្ធតាមរយៈមធ្យោបាយសមរម្យ<br>– កត់ត្រា និងពិចារណាមតិយោបល់ទាំងនោះ។ |
| **៦. សន្និដ្ឋាន** | ពិចារណាអំពីទំហំជាក់លាក់នៃផលប៉ះពាល់ទៅលើជម្រើសនីមួយៗ ដោយជ្រើសរើសយកជម្រើសណាមួយដែលផ្តល់ផលចំណេញដល់សង្គមទាំងមូលប្រសើរជាងគេ។ | – ប្រសិនបើផលប៉ះពាល់ធំគួរឲ្យកត់សម្គាល់ គឺត្រូវបន្តធ្វើការវាយតម្លៃពេញលេញលើផលប៉ះពាល់នោះ(RIS) ។<br>– ផ្សព្វផ្សាយរបាយការណ៍វាយតម្លៃបឋម(PAS)។ បើមិនបន្តធ្វើRISទេ ត្រូវ |

| | | |
|---|---|---|
| | | បញ្ជាក់ពីការជ្រើសរើស ជម្រើសណាមួយដែល មានប្រសិទ្ធភាពបំផុត ដើម្បី ដោះស្រាយបញ្ហា និងសម្រេច គោលបំណងបាន។ |
| **៧. ការអនុវត្ត និងតាមដាន ត្រួតពិនិត្យ** | ពិនិត្យឡើងវិញ/ត្រួតពិនិត្យ ក្រោយពេលអនុវត្ត | – រយៈពេលនៃសុពលភាព របស់បញ្ញត្តិកម្មដែរឬទេ?<br><br>– តើមានផ្សព្វផ្សាយរបាយ ការណ៍ការវាយតម្លៃបឋម ឬពេញលេញ?<br><br>– តើមានយន្តការសម្រាប់ អនុវត្តបានច្បាស់លាស់ ឬអត់? |

ការវាយតម្លៃលើរបាយការណ៍PAS/RIS៖

- ☐ ល្អ
- ☐ កែសម្រួលខ្លះ
- ☐ ធ្វើឡើងវិញ

# ឧបសម្ព័ន្ធ ៣:
# ការគណនាបន្ទុកចំណាយ

## I- សេចក្ដីផ្ដើម

មានវិស័យធំៗចំនួនពីរ នៅពេលធ្វើការពិចារណាលើការវិភាគអំពីបន្ទុកចំណាយក្នុងការធ្វើRIAនៅកម្ពុជាគឺ រដ្ឋាភិបាលនិងធុរកិច្ច។

នៅពេលធ្វើចំណាត់ថ្នាក់លើបន្ទុកចំណាយកាតព្វកិច្ច យើងត្រូវកំណត់កិច្ចការ/សកម្មភាពអនុវត្តតាម ដែលពាក់ព័ន្ធនឹងបទប្បញ្ញត្តិដែលត្រូវបានស្នើឡើង។ ប្រភេទបន្ទុកចំណាយអាចមាន៩ប្រភេទ ដែលប្រភេទខ្លះត្រូវពាក់ព័ន្ធនឹងកិច្ចការអនុវត្តតាម នៅក្នុងសំណើដែលអ្នកមានក្នុងដៃ។ ប្រភេទបន្ទុកចំណាយ គឺជាបន្ទុកចំណាយដែលធុរកិច្ចនិងរដ្ឋាភិបាល ជួបប្រទះក្នុងការបំពេញកិច្ចការណាមួយ។

| | **ចំណាត់ថ្នាក់បន្ទុកចំណាយកាតព្វកិច្ច** | **រដ្ឋាភិបាល** | **ផ្នែកធុរកិច្ច** |
|---|---|---|---|
| **១** | **ការរៀបចំ** | បន្ទុកចំណាយលើការរៀបចំសំណើ<br><br>ឧ. រដ្ឋាភិបាល ត្រូវចាត់តាំងក្រុមការងារធ្វើសេចក្ដីព្រាង និងអនុម័តសំណើ។ | **គ្មាន** |

| | | | |
|---|---|---|---|
| ២ | **ការពិគ្រោះយោបល់** | បន្ទុកចំណាយលើការជូនដំណឹងដល់សាធារណជនអំពីវិធានការណាមួយរបស់ខ្លួន និងការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ។<br><br>ឧ. បន្ទុកចំណាយលើការជូនដំណឹង ការរៀបចំបញ្ជីសំណួរ និងការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ។ | បន្ទុកចំណាយលើការចូលរួមក្នុងកិច្ចពិគ្រោះយោបល់។<br><br>ឧ. ពេលវេលា ដែលត្រូវបានចំណាយ, ការដឹកជញ្ជូន។ |
| ៣ | **ការអប់រំ** | បន្ទុកចំណាយលើការអប់រំភាគីពាក់ព័ន្ធ (រួមទាំងបុគ្គលិករបស់ខ្លួន) អំពីលក្ខខណ្ឌតម្រូវនៃច្បាប់។<br><br>ឧ. បន្ទុកចំណាយលើការបណ្តុះបណ្តាលបុគ្គលិកថ្មី ការបណ្តុះបណ្តាលបុគ្គលិកចាស់ឡើងវិញ ការបណ្តុះបណ្តាលតាមអ៊ិនធឺណិត។ | បន្ទុកចំណាយលើការអប់រំបុគ្គលិក និងបន្តធ្វើបច្ចុប្បន្នភាពលើលក្ខខណ្ឌតម្រូវនៃច្បាប់។<br><br>ឧ. ធុរកិច្ចមួយត្រូវការយល់ដឹងលម្អិតអំពីច្បាប់ថ្មីមួយ និងបណ្តុះបណ្តាល/ប្រាប់អំពីលក្ខខណ្ឌថ្មីៗដល់បុគ្គលិក។ |

| | | | |
|---|---|---|---|
| ៤ | **ការអនុញ្ញាត** | បន្ទុកចំណាយលើត្រួតពិនិត្យលើការកែតម្រូវ និងការផ្តល់ការអនុញ្ញាត ដើម្បីអនុលោមតាមការរៀបចំរដ្ឋបាលផ្សេងៗនៅក្នុងច្បាប់នេះ។<br><br>ឧ. រដ្ឋាភិបាលត្រូវការផ្ទៀងផ្ទាត់ (ពិនិត្យឡើងវិញ)។ ការងារនេះអាចរួមមានការសម្ភាស ការគ្រប់គ្រងលើសំណាក និងការចេញអាជ្ញាប័ណ្ណជាដើម។ | បន្ទុកចំណាយនៅពេលដាក់ពាក្យសុំ (បំពេញបែបបទ) និងរក្សាការអនុញ្ញាតដើម្បីអនុវត្តសកម្មភាពមួយ។<br><br>ឧ. ធុរកិច្ចមួយត្រូវបង់ថ្លៃអាជ្ញាបណ្ណ។ វាក៏បន្តត្រួតពិនិត្យ និងកែលម្អការមិនអនុលោមផ្នែកបច្ចេកទេសដើម្បីទទួលបានការអនុញ្ញាតជាបន្តបន្ទាប់សម្រាប់ប្រតិបត្តិការ។ |
| ៥ | **ការទិញ** | បន្ទុកចំណាយក្នុងការទិញសម្ភារៈ សេវា និងទ្រព្យសម្បត្តិ ដើម្បីគ្រប់គ្រង ដាក់ឲ្យអនុវត្ត ឬអនុលោមតាមច្បាប់<br><br>ឧ. រថយន្ត អគារ ប្រឹក្សាច្បាប់ | បន្ទុកចំណាយលើការទិញសេវា (ការផ្តល់ប្រឹក្សា) ឬផលិតផល (ឧបករណ៍ឬសម្ភារៈ) ដើម្បីអនុលោមតាមច្បាប់ |

| | | | |
|---|---|---|---|
| | | ការពិគ្រោះយោបល់។ | ឧ. ដី បំពង់ពន្លត់អគ្គិភ័យមាននៅកន្លែង (ឧបករណ៍) ឬការផ្តល់ប្រឹក្សាច្បាប់ (សេវា)។ |
| ៦ | **កំណត់ត្រា** | បន្ទុកចំណាយលើការទុកដាក់ និងថែរក្សាកំណត់ត្រា ដើម្បីអនុវត្តតាមវិធានការច្បាប់។<br><br>ឧ. ពេលរៀបចំទុកឯកសារ ការបញ្ចូលទិន្នន័យ ឯកសារអេឡិចត្រូនិក ឯកសារថតចម្លង។ | បន្ទុកចំណាយលើការធ្វើបច្ចុប្បន្នភាពលើឯកសារច្បាប់<br>ឧ. រក្សាកំណត់ត្រាអំពីចំនួនរថយន្តឆ្លងកាត់ស្ពាន ចំនួនភ្ញៀវទេសចរទៅធ្វើទស្សនកិច្ចនៅកន្លែង។ |
| ៧ | **ការបោះពុម្ពផ្សាយ និង ការចែកចាយ** | បន្ទុកចំណាយលើការបោះពុម្ព និងបោះផ្សាយឯកសារពាក់ព័ន្ធនឹងការដាក់ឲ្យប្រើប្រាស់ច្បាប់។<br><br>ឧ. បោះពុម្ពឯកសារច្បាប់ សម្ភារៈសិក្សា  លិខិតស្នាម ការថែទាំឯកសារនៅលើគេហទំព័រ និងតាមអ៊ិនធឺណិត រួមទាំងសិក្ខាសាលាលើកកម្ពស់ការយល់ដឹងផងដែរ។ | បន្ទុកចំណាយលើការផលិតឯកសារឱ្យភាគីទី៣<br>ឧ. ធុរកិច្ចមួយត្រូវបោះពុម្ពសេចក្តីណែនាំ ដល់អ្នកប្រើប្រាស់ ដាក់តាំងផ្លាក់សញ្ញាប្រុងប្រយ័ត្នជាដើម។ |

| | | | |
|---|---|---|---|
| ៨ | **ការដាក់ឲ្យអនុវត្ត** | បន្ទុកចំណាយផ្អែកលើប្រាក់ឈ្នួល ដើម្បីជំរុញអនុវត្ត/អនុវត្តតាមសកម្មភាពអនុវត្តច្បាប់ និងការចំណាយលើការដឹកជញ្ជូន។<br><br>ឧ. មន្ត្រីប្រតិបត្តិ ពេលវេលាត្រូវនៅកន្លែង ការត្រួតពិនិត្យ ការចេញលិខិតពិន័យ និងការជួលឡានជាដើម។ | បន្ទុកចំណាយលើកិច្ចសហការក្នុងសកម្មភាពសវនកម្ម ការត្រួតពិនិត្យ និងការអនុវត្តច្បាប់។<br><br>ឧ. ការទទួលមន្ត្រីអធិការកិច្ចនៅពេលចុះពិនិត្យក្រុមហ៊ុនមួយឲ្យឆ្លើយតបនឹងការតម្រូវរបស់ GMP ដែរឬទេ ផាកពិន័យ |
| ៩ | **ផ្សេងៗ** | បន្ទុកចំណាយផ្សេងទៀត ឬចំណាយមិនមែនរដ្ឋបាលផ្សេងទៀត ដែលមិនស្ថិតនៅក្នុងចំណាត់ថ្នាក់ខាងលើ។ | បន្ទុកចំណាយផ្សេងទៀត ឬចំណាយមិនមែនរដ្ឋបាលផ្សេងទៀតដែលមិនស្ថិតនៅក្នុងប្រភេទខាងលើ។ |

សម្គាល់៖

ក្រៅពី "បន្ទុកចំណាយលើការទិញ" ចំណាត់ថ្នាក់នៃបន្ទុកចំណាយផ្សេងទៀត គឺជាបន្ទុកចំណាយតាមសកម្មភាព។

បន្ទុកចំណាយនេះ អាចជាការចាប់ផ្ដើម ឬជាការបន្ត។

## II- គំរូនៃការគណនា

អាចមានជម្រើស១ឬ២ ស្របជាមួយសំណើច្បាប់។ ជម្រើសនីមួយៗត្រូវគណនាដោយប្រើប្រាស់តារាង Excel : (១)សម្រាប់រដ្ឋាភិបាល និង (២)សម្រាប់ធុរកិច្ច។ ជាលទ្ធផលតារាងសង្ខេបត្រូវបានរៀបចំឡើង ដោយរួមបញ្ចូលទាំងបន្ទុកចំណាយរដ្ឋាភិបាលនិងចំណាយធុរកិច្ច។

## ១) ចំណាយរដ្ឋាភិបាល

| ព័ត៌មានទូទៅ |
|---|
| ជម្រើសទី ១ : សំណើ |
| ចំណងជើង : ខ. ការចេញអាជ្ញាប័ណ្ណធុរកិច្ចទេសចរណ៍ សម្រាប់កន្លែងទេសចរណ៍ |
| ថ្ងៃចេញអាជ្ញាបណ្ណ : ២០១៣ (សេចក្តីព្រាង) |
| ក្រសួង : ក្រសួងទេសចរណ៍ |

### ១-១ ការតាក់តែងច្បាប់

ក) ការធ្វើសេចក្តីព្រាងច្បាប់ (ឧទាហរណ៍)

<table>
<tr><td rowspan="6">អក្សរកាត់<br><br>T = ពេលដែលបានចំណាយ<br><br>N = ចំនួនបុគ្គលិក /អគារ /ទីតាំង<br><br>W = អត្រាប្រាក់ឈ្នួល<br><br>V = តម្លៃ</td><td>មុខទំនិញ</td><td>T</td><td>N</td><td>W</td><td>V</td></tr>
<tr><td>ផ្នែកបច្ចេកទេស</td><td></td><td></td><td></td><td></td></tr>
<tr><td>ផ្នែកច្បាប់</td><td></td><td></td><td></td><td></td></tr>
<tr><td>ក្រុមការងាររដ្ឋបាល</td><td></td><td></td><td></td><td></td></tr>
<tr><td>...</td><td></td><td></td><td></td><td></td></tr>
<tr><td colspan="4">សរុប = ΣV = Σ(T×N×V)</td><td>?</td></tr>
</table>

## ខ) ការអនុម័តច្បាប់ (កម្រិតក្រសួង)

| *មុខទំនិញ* | *T* | *N* | *W* | *V* |
|---|---|---|---|---|
| កិច្ចប្រជុំពិភាក្សាដែលផ្តួចផ្តើមដោយរដ្ឋមន្ត្រី | | | | |
| ការពិនិត្យឡើងវិញ | | | | |
| | សរុប | | | |

## គ) ការអនុម័តច្បាប់ (កម្រិតគណៈរដ្ឋមន្ត្រី)

| *មុខទំនិញ* | *T* | *N* | *W* | *V* |
|---|---|---|---|---|
| កិច្ចប្រជុំបច្ចេកទេស | | | | |
| កិច្ចប្រជុំរួម | | | | |
| | សរុប | | | |

| | |
|---|---|
| ការរៀបចំសរុប | |

## ១-២ ការពិគ្រោះយោបល់ (ផ្អែកលើវិធីសាស្ត្រ)

| ពាក្យកាត់ | *មុខទំនិញ* | *T* | *N* | *P* | *V* |
|---|---|---|---|---|---|
| P = ថ្លៃ | ការទៅមើលទីតាំងកិច្ចសម្ភាសន៍<br>សិក្ខាសាលា<br>ការហៅទូរសព្ទ | | | | |
| | ... | | | | |
| | | សរុប | | | |

| | |
|---|---|
| ការពិគ្រោះយោបល់សរុប | |

## ១-៣ ការអប់រំ

### ក) ការបណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបាល

| *មុខទំនិញ* | *T* | *N* | *P* | *V* |
|---|---|---|---|---|
| | | | | |
| | សរុប | | | |

### ខ) ការបណ្តុះបណ្តាលបុគ្គលិកភាគីពាក់ព័ន្ធ

| *មុខទំនិញ* | *T* | *N* | *P* | *V* |
|---|---|---|---|---|
| | | | | |
| | សរុប | | | |

| | |
|---|---|
| ការអប់រំសរុប | |

## ១.៤- ការអនុញ្ញាត

### ក) ការផ្ទៀងផ្ទាត់

| *មុខទំនិញ* | *T* | *N* | *W* | *V* |
|---|---|---|---|---|
| ឯកសារ;ការពិនិត្យបន្ទប់ពិសោធន៍; | | | | |
| … | សរុប | | | |

### ខ) ការចេញអាជ្ញាបណ្ណ

| *មុខទំនិញ* | *N* | *P* | *V* |
|---|---|---|---|
| ការចេញអាជ្ញាបណ្ណ | | | |
| … | | | |
| | សរុប | | |

| | |
|---|---|
| ការអនុញ្ញាតសរុប | |

## ១.៥- ការទិញ

### ក) ការទិញទំនិញ

| *មុខទំនិញ* | *N* | *P* | *V* |
|---|---|---|---|
| .. | | | |
| | សរុប | | |

ខ) ការទិញសេវា

| *មុខទំនិញ* | ***N*** | ***P*** | ***V*** |
|---|---|---|---|
| .. | | | |
| | សរុប | | |

| ការទិញសរុប | |
|---|---|

## ១.៦- ការរក្សាកំណត់ត្រា

| *មុខទំនិញ* | ***T*** | ***N*** | ***W*** | ***V*** |
|---|---|---|---|---|
| ការចុះបញ្ជីទិន្នន័យ | | | | |
| ការធ្វើបច្ចុប្បន្នកម្មទិន្នន័យ | | | | |
| ... | | | | |
| | សរុប | | | |

| ការរក្សាកំណត់ត្រាសរុប | |
|---|---|

## ១.៧- ការបោះពុម្ពផ្សាយ និងការចែកចាយ

ក) ការបោះពុម្ពផ្សាយ

| *មុខទំនិញ* | *N* | *P* | *V* |
|---|---|---|---|
| .. | | | |
| | សរុប | | |

ខ) ការចែកចាយ

| *មុខទំនិញ* | *N* | *P* | *V* |
|---|---|---|---|
| .. | | | |
| | សរុប | | |

| | |
|---|---|
| ការបោះពុម្ពផ្សាយ និងការចែកចាយសរុប | |

## ១.៨- ការអនុវត្ត

### ក) ការត្រួតពិនិត្យទីកន្លែង

| *ចំណុច* | *T* | *N* | *W* | *V* |
|---|---|---|---|---|
| ... | | | | |
| | សរុប | | | |

### ខ) ថ្លៃដឹកជញ្ជូន

| *មុខទំនិញ* | *T* | *N* | *W* | *V* |
|---|---|---|---|---|
| ... | | | | |

| | | |
|---|---|---|
| | សរុប | |

### គ) ថ្លៃធ្វើរបាយការណ៍

| *មុខទំនិញ* | *T* | *N* | *W* | *V* |
|---|---|---|---|---|
| ... | | | | |
| | សរុប | | | |

| | |
|---|---|
| ការអនុវត្តសរុប | |

## ១.៩- ផ្សេង

| | *មុខទំនិញ* | *T* | *N* | *W* | *V* |
|---|---|---|---|---|---|
| | ... | | | | |
| | | សរុប | | | |

| | |
|---|---|
| ចំណាយសរុបចំពោះរដ្ឋាភិបាល | |

## ២) បន្ទុកចំណាយផ្នែកធុរកិច្ច

### ២.១- ការរៀបចំបទបញ្ញត្តិ

គ្មាន

### ២.២- ការពិគ្រោះយោបល់ (ឧទាហរណ៍)

| ពាក្យកាត់ | *មុខទំនិញ* | *T* | *N* | *P* | *V* |
|---|---|---|---|---|---|
| P = ថ្លៃ | ការចូលរួម | | | | |
| | ការរៀបចំ | | | | |
| | | សរុប | | | |

| | |
|---|---|
| ការផ្តល់ប្រឹក្សាសរុប | |

### ២.៣- ការអប់រំ

| *មុខទំនិញ* | *T* | *N* | *P* | *V* |
|---|---|---|---|---|
| បុគ្គលិកបណ្ដុះបណ្ដាល | | | | |
| ... | | | | |
| | សរុប | | | |

| | |
|---|---|
| ការអប់រំសរុប | |

## ២.៤- ការអនុញ្ញាត

| *មុខទំនិញ* | *N* | *P* | *V* |
|---|---|---|---|
| ថ្លៃអាជ្ញាបណ្ណ | | | |
| ... | | | |
| | សរុប | | |

| | |
|---|---|
| ការអនុញ្ញាតសរុប | |

## ២.៥- ការទិញ

### ក) ការទិញទំនិញ

| *មុខទំនិញ* | *N* | *P* | *V* |
|---|---|---|---|
| .. | | | |
| | សរុប | | |

### ខ) ការទិញសេវា

| *មុខទំនិញ* | *N* | *P* | *V* |
|---|---|---|---|
| .. | | | |
| | សរុប | | |

| | |
|---|---|
| ការទិញសរុប | |

## ២.៦- ការរក្សាកំណត់ត្រា

| *មុខទំនិញ* | *T* | *N* | *W* | *V* |
|---|---|---|---|---|
| កំណត់ត្រាទិន្នន័យ | | | | |
| ... | | | | |
| | សរុប | | | |

| | |
|---|---|
| ការរក្សាកំណត់ហេតុសរុប | |

## ២.៧- ការបោះពុម្ពផ្សាយ និងការចែកចាយ

### ក) ការបោះពុម្ពផ្សាយ

| *មុខទំនិញ* | *N* | *P* | *V* |
|---|---|---|---|
| .. | | | |
| | សរុប | | |

### ខ) ការចែកចាយ

| *មុខទំនិញ* | *N* | *P* | *V* |
|---|---|---|---|
| .. | | | |
| | សរុប | | |

| | |
|---|---|
| ការបោះពុម្ពផ្សាយ និងការចែកចាយសរុប | |

## ២.៨- ការដាក់ឲ្យអនុវត្ត

### ក) ការត្រួតពិនិត្យទីកន្លែង

| *មុខទំនិញ* | *T* | *N* | *W* | *V* |
|---|---|---|---|---|
| ... | | | | |
| | សរុប | | | |

### ខ) ថ្លៃដឹកជញ្ជូន

| *មុខទំនិញ* | *T* | *N* | *W* | *V* |
|---|---|---|---|---|
| ... | | | | |
| | សរុប | | | |

### គ) ថ្លៃធ្វើរបាយការណ៍

| *មុខទំនិញ* | *T* | *N* | *W* | *V* |
|---|---|---|---|---|
| ... | | | | |
| | សរុប | | | |

| | |
|---|---|
| ការដាក់ឲ្យអនុវត្តសរុប | |

## ២.៩- ផ្សេង

| *មុខទំនិញ* | *T* | *N* | *W* | *V* |
|---|---|---|---|---|
| ... | | | | |
| | សរុប | | | |

| | |
|---|---|
| ចំណាយសរុបចំពោះធុរកិច្ច | |

## ៣- សង្ខេប

| ល.រ. | ចំណាត់ថ្នាក់ | បន្ទុកចំណាយរដ្ឋាភិបាល | បន្ទុកចំណាយធុរកិច្ច | បន្ទុកចំណាយសរុបនៃប្រភេទនីមួយៗ |
|---|---|---|---|---|
| ១ | ការរៀបចំ | | | |
| ២ | ការពិគ្រោះយោបល់ | | | |
| ៣ | ការអប់រំ | | | |
| ៤ | ការអនុញ្ញាត | | | |
| ៥ | ការទិញ | | | |
| ៦ | ការរក្សាកំណត់ត្រា | | | |
| ៧ | ការបោះពុម្ពផ្សាយ និងការចែកចាយ | | | |
| ៨ | ការដាក់ឱ្យអនុវត្ត | | | |
| ៩ | ផ្សេងៗ | | | |
| | **សរុប** | | | |

ហិរញ្ញប្បទាន
ដោយ
ធនាគារអភិវឌ្ឍន៍អាស៊ី

ADB